ក

# មាតិកា

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី២៣ ខែ៣ ឆ្នាំ2000

## I- ខុទ្ទកាល័យព្រះមហាក្សត្រ

### ១-ព្រះរាជក្រឹត្យ


០៣-៨-១៩៩៩ - ព្រះរាជក្រឹត្យ ជស/រកត/០៧៩៩/៥០ តែងតាំងឯកឧត្តម នុច ថន ជាទីប្រឹក្សាផ្ទាល់ សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា ១៤៣៣

០៤-៨-១៩៩៩ -ព្រះរាជក្រឹត្យ ជស/រកត/០៨៩៩/៥១ ត្រូវបានតែងតាំងឯកឧត្តម ខឹម សោគ័ណ ជាអគ្គនាយកមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា ១៤៣៤

០៤-៨-១៩៩៩ -ព្រះរាជក្រឹត្យជស/រកត/០៨៩៩/៥២ តែងតាំងឯកឧត្តម គ្រីយ៍ បេងឃុន ជាទីប្រឹក្សាផ្ទាល់សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា ១៤៣៥


## II- រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ


០៣-៨-១៩៩៩ - អនុក្រឹត្យ លេខ ៦៧ អនក្រ.បក ស្តីពីការរៀបចំការប្រព្រឹត្តិទៅរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ១៤៣៦

០៤-៨-១៩៩៩ - អនុក្រឹត្យ លេខ ៦៨ អនក្រ.បក ស្តីពីការ ផ្ទេរឥណទាន ១៤៤៧

០៤-៨-១៩៩៩ - អនុក្រឹត្យ លេខ ៦៩ អនក្រ.បក ស្តីពីការផ្តល់ប្រាក់បំណាច់បន្ថែមលើបៀវត្ស ប្រចាំខែ សំរាប់អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ អគ្គនាយកដ្ឋាននគរបាលជាតិ និងអគ្គនាយកដ្ឋានចំណុះក្រសួងការពារជាតិ ១៤៤៨

០៥-៨-១៩៩៩ - អនុក្រឹត្យ លេខ ៧០ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងពត៌មាន ១៤៥០

០២-៨-១៩៩៩ - អនុក្រឹត្យ លេខ ៤៥០ អនក្រ.តត ស្តីពីការតែងតាំង ឋានន្តរស័ក្តិនាយកនគរបាលជាតិ ១៤៦៩

០២-៨-១៩៩៩ - អនុក្រឹត្យ លេខ ៤៥១ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៤៧០

០២-៨-១៩៩៩ - អនុក្រឹត្យ លេខ ៤៥២ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៤៧០

០២-៨-១៩៩៩ - អនុក្រឹត្យ លេខ ៤៥៣ អនក្រ.តត ស្តីពីការផ្លាស់ប្តូរមន្ត្រីរបស់មជ្ឈមណ្ឌល សកម្មភាពកំចាត់មីនកម្ពុជា (CMAC) ១៤៧១

០៣-៨-១៩៩៩ - អនុក្រឹត្យ លេខ ៥៥៤ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៥៧២

០៥-៨-១៩៩៩ - អនុក្រឹត្យ លេខ ៥៥៥ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិ តែងតាំង និង ផ្លាស់ប្តូរមុខងារ ១៥៧៣

០៥-៨-១៩៩៩ -អនុក្រឹត្យ លេខ ៥៥៦ អនក្រ.តត ស្តីពីការដាក់អោយចូលនិវត្តន៍របស់មន្ត្រីរាជការ ១៥៧៤


## VI- ការងារបណ្តាក្រសួង

### ១-ទីស្តីការរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

#### ១-សារាចរ


០៣-៨-១៩៩៩ - សារាចរលេខ ០១២ សរ.សហវ ស្តីពីការប្រមូលចំណូលពីទ្រព្យសម្បត្តិសាធារណៈ ១៥៧៥


### ២-ធនាគារជាតិនៃកម្ពុជា

#### ប្រកាស


០៥-៨-១៩៩៩ - ប្រកាស លេខ ធ ៩៩៨-៣៨៣ ប្រក ស្តីពីការគ្រប់គ្រងការប្តូរប្រាក់ចំពោះអាជីវករ ប្តូរប្រាក់ ១៥៧៧


### ៣-ទីស្តីការរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

#### ប្រកាស


០៤-៨-១៩៩៩ - ប្រកាស លេខ ៣៩៥ បល-ប្រក ស្តីពីការបង្កើតមន្ទីរពាណិជ្ជកម្មខេត្តឧត្តរមានជ័យ ១៥៨០


### ៤-ទីស្តីការ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

#### ប្រកាស


០៦-៨-១៩៩៩ -ប្រកាស លេខ ៧៧២ ផក-ប្រក អនុញ្ញាតអោយក្រុមហ៊ុន ឈីង ស៊ីង (ខេមបូឌា) ហ្គាមែន ហ្វេកធើរី (CUNG SING) (CAMBODIA) GARMENT FACTORY LTD តំណាង ដោយលោក GSUN SHU YAN សញ្ជាតិចិន បង្កើតរោងចក្រ កាត់ដេរ សំលៀកបំពាក់ ១៥៨១

# គ

## ៥-ទីស្តីការរដ្ឋមន្ត្រី ក្រសួងធម្មការ និងសាសនា

### ប្រកាស


| | | |
|---|---|---|
| ០៦-៨-១៩៩៩ | - ប្រកាស លេខ ១៣៥ កធស.ប្រក ស្តីពីការតែងតាំង មន្ត្រីរាជការ | ១៤៨២ |
| ០៥-៨-១៩៩៩ | - ប្រកាស លេខ ១៤២ កធស-ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ | ១៤៨៣ |

# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ១-ព្រះរាជក្រឹត្យ

### ព្រះរាជក្រឹត្យ នស/រកត/០៧៩៩/៥០

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជហរិវង្ស**

**ឧភតោសុជាតិ វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

* * *

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើជាផ្លូវការ នូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយ នៃជំពូកទី ៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៥៣ ចុះថ្ងៃទី១១ ខែ មីនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យតែងតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា

-យោងតាមសំណូមពរចាំបាច់នៃការងារ ។

**ត្រាស់បង្គាប់**

**មាត្រា ១** .-តែងតាំងឯកឧត្តម **នុច ថន** ជាទីប្រឹក្សាផ្ទាល់សម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ទទួលបន្ទុកកិច្ចការការពារជាតិ មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

**មាត្រា ២** .-ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** .-ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ១៩៩៩

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

**ជា ស៊ីម**

***

# ព្រះរាជក្រឹត្យ ជស/រកត/០៨៩៩/៥១

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជហរិវង្ស

## ឧភតោសុជាតិ វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

## ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

* * *

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការ ប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦៩៩/១៣៤ ចុះថ្ងៃទី២១ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា

-យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ ១៩៩៩ ។

## ត្រាស់បង្គាប់

**មាត្រា១.-** ត្រូវបានតែងតាំងឯកឧត្តម ខឹម សោភ័ណ ជាអគ្គនាយក មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា (CMAC)ជំនួសឯកឧត្តម **សម សុគ្គា** ដែលត្រូវបានផ្លាស់ចេញទៅបំពេញភារកិច្ចថ្មី ។

**មាត្រា ២ .-** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ .-** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ១៩៩៩

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

★★★

# ព្រះរាជក្រឹត្យ ជស/រកត/០៨៩៩/៥២

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជហរិវង្ស

ឧភតោសុជាតិ វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលប្រកាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយ នៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩ ដែលព្រះរាជបង្គាប់តែងតាំង ប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី១១ ខែ មីនា ឆ្នាំ ១៩៩៩ ដែលប្រកាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា

-យោងតាមសេចក្តីត្រូវការចាំបាច់នៃការងារ ។

## ត្រាស់បង្គាប់

**មាត្រា ១ .**-តែងតាំងឯកឧត្តម **គ្រឹយ៍ មេងហុង** ជាទីប្រឹក្សាផ្ទាល់សម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ទទួលបន្ទុកការងារនគរូបនីយកម្ម និងសំណង់ មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

**មាត្រា ២ .**-ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ .**-ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ១៩៩៩

ក្នុងព្រះបរមនាម និងតាមព្រះរាជព្រះរាជបង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

***

# II- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យ លេខ ៦៧ អនក្រ/បក
### ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងទំនាក់ទំនង ជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច

* * *

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៥ ចុះថ្ងៃទី១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច

-បានឃើញអនុក្រឹត្យលេខ ២០ អនក្រ/បក ចុះថ្ងៃទី៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន

-បានការឯកភាពពីគណៈរដ្ឋមន្ត្រី នាសម័យប្រជុំពេញអង្គ ថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៩

**សំរេច**

**ជំពូកទី១**
**បទប្បញ្ញត្តិទូទៅ**

**មាត្រា ១ .-**

អនុក្រឹត្យនេះ កំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ព្រមទាំងកំណត់បេសកកម្មរបស់ក្រសួង និងមុខងារនៃអង្គភាពក្រោមឱវាទ និងបណ្តាអង្គភាពចំណុះ ។

**ជំពូកទី២**
**បេសកកម្ម និង រចនាសម្ព័ន្ធ**

**មាត្រា ២ .-**

ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ត្រូវបានរាជរដ្ឋាភិបាលប្រគល់បេសកកម្មអោយដឹកនាំគ្រប់គ្រង រាល់កិច្ចការសំរបសំរួល ធ្វើទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងធ្វើអធិការ

កិច្ច សេរីគ្រប់ជ្រុងជ្រោយ នៅក្នុងព្រះរាជាណាចក្រកម្ពុជា សំដៅប្រឆាំងនឹងអំពើពុករលួយ ការរំលោភលើអំណាច និងបាតុភាពអសកម្ម ។

មាត្រា ៣ .-

ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច មានភារកិច្ច និង សិទ្ធិដូចតទៅ :

ក-<u>វិស័យការងារទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា</u>

-ផ្តួចផ្តើម និងសំរបសំរួលទំនាក់ទំនងរាល់ការងារ រវាងរាជរដ្ឋាភិបាល និងរដ្ឋសភា ព្រឹទ្ធសភា

-ចូលរួមរៀបចំប្រតិទិនការងារ រវាងរាជរដ្ឋាភិបាល និង ផែនការ ការងាររបស់រដ្ឋសភា ព្រឹទ្ធសភា

-ចូលរួមប្រជុំអន្តរក្រសួងពិនិត្យពិភាក្សារាល់សេចក្តីព្រាងច្បាប់នានា ដែលរៀបចំដោយទីស្តីការគណៈរដ្ឋមន្ត្រី

-ចូលរួមប្រជុំជាមួយគណៈកម្មាធិការអចិន្ត្រៃយ៍ និង គណៈកម្មការបច្ចេកទេស នៃរដ្ឋសភា ព្រឹទ្ធសភា តាមការអញ្ជើញរបស់ រដ្ឋសភា ព្រឹទ្ធសភា

-ជួយអន្តរាគមន៍អោយមានវត្តមានរដ្ឋមន្ត្រីសាមីបញ្ហា ឬ អ្នកតំណាងជាប្រចាំសំរាប់ការពារនៅពេលដែលរដ្ឋសភា ព្រឹទ្ធសភា កោះអញ្ជើញ

-ស្វែងយល់ពីការលំបាក រវាងអង្គការនីតិប្រតិបត្តិ និង អង្គការនីតិបញ្ញត្តិ ដើម្បីធ្វើការសំរបសំរួល

-រៀបចំកម្មវិធីផ្សព្វផ្សាយច្បាប់ ជូនប្រជាពលរដ្ឋអោយបានដឹង និងប្រតិបត្តិតាមទូទាំងព្រះរាជាណាចក្រកម្ពុជា

ខ-<u>វិស័យការងារអធិការកិច្ច</u>

-ទទួលរាល់កិច្ចការ ដែលរាជរដ្ឋាភិបាលប្រគល់អោយ រួមទាំងលទ្ធផលអធិការកិច្ចថ្នាក់ក្រោម ដែលមានការតវ៉ា ធ្វើពុំទាន់បានត្រឹមត្រូវ ដើម្បីចាត់ចែងអោយធ្វើអង្កេតស្រាវជ្រាវជាថ្មី រួចសន្និដ្ឋាន និងលើកសំណូមពរ ជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យសំរេច

-តាមដាន និងធ្វើអធិការកិច្ច រាល់ការអនុម័តសេចក្តីសំរេច របស់រាជរដ្ឋាភិបាលដែលបានចូលជាធរមាន

-ផ្តួចផ្តើមគំនិត និងចាត់តាំងគណៈប្រតិភូ ឬបេសកជន អោយចុះធ្វើអធិការកិច្ចសេរីគ្រប់ជ្រុងជ្រោយ នៅតាមក្រសួង រដ្ឋលេខាធិការដ្ឋាន ខេត្ត-ក្រុង គ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈ ដើម្បីតាមដានការអនុវត្តន៍ច្បាប់ និងលិខិតបទដ្ឋាននានា

-ដឹកនាំលើការងារអធិការកិច្ច ធ្វើការទំនាក់ទំនងជាមួយបណ្តាអគ្គាធិការដ្ឋាន របស់បណ្តាក្រសួង ស្ថាប័ន ខេត្ត-ក្រុង និងស្នើសុំអោយមានកិច្ចសហប្រតិបត្តិការក្នុងករណីចាំបាច់

-លើកវិធានការដើម្បីបង្ក្រាបរាល់អំពើអសកម្ម និងអំពើពុករលួយក្នុងជួរមន្ត្រីរាជការស៊ីវិល មន្ត្រីយោធា និងមន្ត្រីនគរបាលជាតិ ដែលធ្វើអោយប៉ះពាល់ដល់ការស្តារ និង អភិវឌ្ឍន៍ជាតិ

-អញ្ជើញជនដែលពាក់ព័ន្ធ តាមរយៈសមត្ថកិច្ចដែលគ្រប់គ្រងជនទាំងនោះ ដើម្បីមកបំភ្លឺ សាកសួរ ស្រាវជ្រាវ ពត៌មាន ពិនិត្យឯកសារ និង ចូលរួមសហការក្នុងសកម្មភាពអធិការកិច្ច ។ ក្នុងករណីមិនបានអញ្ជើញមក ចំនួន០៣លើក ក្រសួងនឹងចាត់ចែងតាមនីតិវិធី

-ក្នុងពេលស៊ើបអង្កេត ស្រាវជ្រាវ ប្រមូលឯកសារពាក់ព័ន្ធ ក្រសួងអាចផ្អាកការងារនៃមន្ត្រីរាជការ ដែលមិនព្រមចូលរួមសហការក្នុងការងារអធិការកិច្ច ដោយមានការឯកភាពពីប្រធានស្ថាប័នសាមី ចំពោះមន្ត្រីដែលមានឋានៈពីអនុប្រធាននាយកដ្ឋានចុះ និងឯកភាពពីប្រមុខរាជរដ្ឋាភិបាល ចំពោះមន្ត្រីដែលមានឋានៈពីប្រធាននាយកដ្ឋានឡើង

-ផ្អាកជាបណ្តោះអាសន្ន ចំពោះការអនុវត្តន៍ទាំងឡាយណាដែលបានពិនិត្យឃើញថា បង្កនូវអហេតុភាពធ្ងន់ធ្ងរ ប៉ះពាល់ដល់ផលប្រយោជន៍ជាតិ សាធារណៈ និង ប្រជាពលរដ្ឋ រួចរៀបចំសំណុំរឿងដាក់ជូនប្រមុខរាជរដ្ឋាភិបាលសំរេច

-ក្រោយពេលធ្វើអធិការកិច្ចមួយលើកៗ ត្រូវធ្វើរបាយការណ៍អំពីសកម្មភាព និងលទ្ធផលការងារអធិការកិច្ច ដោយធ្វើការសន្និដ្ឋាន និងសំណើមការចាត់វិធានការជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យសំរេច

-កសាងសំណុំរឿងដាក់ជូនប្រមុខរាជរដ្ឋាភិបាលដើម្បីពិនិត្យ បញ្ជូនទៅតុលាការធ្វើការវិនិច្ឆ័យទោសតាមច្បាប់ ចំពោះរូបវ័ន្តបុគ្គល ឬនីតិបុគ្គល ដែលបានប្រព្រឹត្តល្មើសនឹងច្បាប់ ឬអនុវត្តខុសពីតួនាទី ធ្វើអោយប៉ះពាល់ដល់នយោបាយ សេដ្ឋកិច្ច ថវិកា ឬប្រើសិទ្ធិអំណាចបង្កការរាំងស្ទះ ក្នុងពេលធ្វើអធិការកិច្ច

-អាចផ្សព្វផ្សាយជាសាធារណៈ នូវលទ្ធផលនៃការធ្វើអធិការកិច្ច ដែលរាជរដ្ឋាភិបាលបានពិនិត្យសំរេចរួចហើយ ។

-ធ្វើរបាយការណ៍អំពីសកម្មភាព និងលទ្ធផលការងារ ទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ជូនរាជរដ្ឋាភិបាល ប្រចាំត្រីមាស ឆមាស និងឆ្នាំ

-នៅពេលចាំបាច់អាចចាត់តាំងធ្វើសិក្ខាសាលា ឬសន្និបាតផ្សព្វផ្សាយ អំពីការងារទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច

-ចេញប្រកាសសេចក្តីសំរេច បទបញ្ជា សារាចរ សេចក្តីណែនាំ និងសេចក្តីជូនដំណឹងផ្សេងៗ ដើម្បីបំពេញបេសកកម្មរបស់ខ្លួន និងដើម្បីអនុវត្តខ្លឹមសារ នៃលិខិតបទដ្ឋានគតិយុត្ត របស់រាជរដ្ឋាភិបាល

-ទទួលនូវប្រាក់រង្វាន់មួយចំនួន តាមការកំណត់របស់ប្រមុខរាជរដ្ឋាភិបាល នៅលើទឹកប្រាក់ដែលបានរកឃើញពីការបំបាត់ ដើម្បីលើកទឹកចិត្តជូនដល់មន្ត្រីរបស់ក្រសួង ដែលមានស្នាដៃ ។

មាត្រា ៤ .-

រចនាសម្ព័ន្ធក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច មានដូចតទៅ :

-ខុទ្ទកាល័យរដ្ឋមន្ត្រី

-អគ្គនាយកដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា រួមមាន :

- នាយកដ្ឋាននីតិកម្ម
- នាយកដ្ឋានទំនាក់ទំនងរាជរដ្ឋាភិបាល និង រដ្ឋសភា ព្រឹទ្ធសភា
- នាយកដ្ឋានអប់រំសិក្សា ផ្សព្វផ្សាយច្បាប់

-អគ្គនាយកដ្ឋានអធិការកិច្ច រួមមាន :

- នាយកដ្ឋានទំនាក់ទំនងជាមួយអធិការកិច្ច តាមបណ្តាស្ថាប័ន
- នាយកដ្ឋានអធិការកិច្ច

- នាយកដ្ឋានតាមដានការអនុវត្តន៍ច្បាប់
- នាយកដ្ឋានទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវ
- នាយកដ្ឋាន វិវាទកម្ម

-អគ្គនាយកដ្ឋានរដ្ឋបាលកិច្ចការទូទៅ រួមមាន :

- នាយកដ្ឋានរដ្ឋបាល និង បុគ្គលិក
- នាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់
- អង្គភាពមូលដ្ឋាន ខេត្ត-ក្រុង

អង្គការលេខរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និង អធិការកិច្ច ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

## ជំពូកទី៣
## ខុទ្ទកាល័យរដ្ឋមន្ត្រី

**មាត្រា៥ .-**

ខុទ្ទកាល័យរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្ម និង ភារកិច្ចទាំងឡាយដែលមានកំណត់ តាមបញ្ញត្តិនៃអនុក្រឹត្យ លេខ២០ អនក្រ-បក ចុះថ្ងៃទី៣០ ខែ មេសា ឆ្នាំ១៩៩៦ ដូចមានចែងក្នុងមួយលេខពាងលើស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន ។

## ជំពូកទី៤
## អគ្គនាយកដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា

**មាត្រា ៦ .-**

អគ្គនាយកដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា មានភារកិច្ចធ្វើជាសេនាធិការអោយក្រសួង លើការងារ :

-សំរបសំរួល និងគ្រប់គ្រងការងារទំនាក់ទំនងលើកសេចក្តីច្បាប់ការងារ ទំនាក់ទំនងរាជរដ្ឋាភិបាល និងរដ្ឋសភា ព្រឹទ្ធសភា ការងារអប់រំ សិក្សាផ្សព្វផ្សាយច្បាប់ ។

អគ្គនាយកដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា ដឹកនាំដោយអគ្គនាយកមួយរូប និង មានអគ្គនាយករងមួយចំនួនជាជំនួយការ តាមការចាំបាច់ ។

អគ្គនាយកដ្ឋាននេះ មាននាយកដ្ឋានចំណុះ ដូចមានចែងក្នុងមាត្រាខាងក្រោម :

**មាត្រា ៧ .-**

នាយកដ្ឋាននីតិកម្ម មានភារកិច្ច :

-សិក្សាស្រាវជ្រាវឯកសារច្បាប់គ្រប់វិស័យ គ្រប់ជំនាន់ ក្នុង និងក្រៅប្រទេស ដើម្បីស្វែងយល់ពីផលល្អ និងផលអាក្រក់ជំរាបជូនរដ្ឋមន្ត្រី

-រៀបចំសេចក្តីព្រាងច្បាប់នានា ដែលរាជរដ្ឋាភិបាលប្រគល់អោយ ដើម្បីដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យ និងសំរេច ចូលរួមពិនិត្យ និង ធ្វើការវិភាគ ពាក្យបណ្តឹងដែលក្រសួងបានទទួល

-សហការជាមួយនាយកដ្ឋានពាក់ព័ន្ធ ក្នុងការស្វែងយល់អំពីប្រព័ន្ធច្បាប់អោយបានសុក្រិត្យ

នាយកដ្ឋាននេះដឹកនាំដោយប្រធាន ០១រូប និងមានអនុប្រធានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

មាត្រា ៨ .-

នាយកដ្ឋានទំនាក់ទំនងរាជរដ្ឋាភិបាល និង រដ្ឋសភា ព្រឹទ្ធសភា មានភារកិច្ច :

-ចាំនាំចំឡើយពីស្ថាប័ននានាជូនរដ្ឋមន្ត្រី បញ្ហាដែលរដ្ឋសភា ព្រឹទ្ធសភាចោទសួររាជរដ្ឋាភិបាល

-លើកយកការរាំបាក់នៃសេចក្តីព្រាងច្បាប់ និងការអនុវត្តន៍ច្បាប់របស់រាជរដ្ឋាភិបាល ដើម្បីធ្វើការសំរប . សំរួល ជាមួយរដ្ឋសភា ព្រឹទ្ធសភា

-ស្រាវជ្រាវលើកយោបល់ជូនប្រធានស្ថាប័ន ដើម្បីស្នើសុំពិគ្រោះជាមួយទីស្តីការគណៈរដ្ឋមន្ត្រី គណៈកម្មាធិការអចិន្ត្រៃយ៍ គណៈកម្មការបច្ចេកទេស និងអគ្គលេខាធិការដ្ឋានរដ្ឋសភា ព្រឹទ្ធសភា ដើម្បីយល់ដឹងពីការងាររបស់រាជរដ្ឋាភិបាល និងរដ្ឋសភា ព្រឹទ្ធសភា ងាយស្រួលសំរបសំរួល ធ្វើអោយសម័យប្រជុំពេញ អង្គរដ្ឋសភា ព្រឹទ្ធសភា ទទួលបានជោគជ័យ ។

-ចូលរួមស្តាប់ និងជំរុញអោយប្រធានស្ថាប័ន ក្នុងការប្តឹត្រួតពិនិត្យតាមដានការប្រជុំនៃគណៈកម្មការបច្ចេកទេស របស់រដ្ឋសភា ព្រឹទ្ធសភា ក្នុងនាមជាតំណាងក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ដើម្បីតាមដានរាល់សេចក្តីព្រាងច្បាប់ដែលបានបញ្ជូនទៅរដ្ឋសភា ព្រឹទ្ធសភា និងធ្វើការសំរបសំរួល ជាមួយអគ្គលេខាធិការដ្ឋានរដ្ឋសភា ព្រឹទ្ធសភា សំរាប់ត្រៀមរបៀបវារៈរៀបចំរបៀបវារៈ ជូនរដ្ឋសភា ព្រឹទ្ធសភា ក្នុងកិច្ចប្រជុំពេញអង្គ

-ផ្តល់យោបល់ជូនប្រធានស្ថាប័ន លើការពិភាក្សាសេចក្តីព្រាងច្បាប់ អនុក្រឹត្យរបស់រាជរដ្ឋាភិបាលរបស់រាល់ក្រសួង រដ្ឋលេខាធិការដ្ឋាននានា ដើម្បីយល់ដឹងពីភាពស្មុគស្មាញ នៃសេចក្តីព្រាងច្បាប់ និងអនុក្រឹត្យទាំងនោះ

-ធ្វើតុល្យការការងារ ដែលរដ្ឋសភា ព្រឹទ្ធសភា បានអនុម័ត និងមិនទាន់អនុម័ត ក្នុងសម័យប្រជុំនីមួយៗ

នាយកដ្ឋាននេះដឹកនាំដោយប្រធាន០១រូប និងមានអនុប្រធានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

មាត្រា៩ .-

នាយកដ្ឋានអប់រំសិក្សា ផ្សព្វផ្សាយច្បាប់ មានភារកិច្ច :

-ធ្វើការអប់រំសិក្សាផ្សព្វផ្សាយច្បាប់ ដែលចូលជាធរមានរួចហើយ ជូនសាធារណជន ប្រជាពលរដ្ឋ តាមវិទ្យុទូរទស្សន៍ និងព្រឹត្តិប័ត្រ ដើម្បីអោយប្រជាពលរដ្ឋបានយល់ដឹង និងគោរពប្រតិបត្តិតាម

-ធ្វើសហប្រតិបត្តិការជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធ ដើម្បីចុះធ្វើការអប់រំផ្សព្វផ្សាយ និងគោលនយោបាយរបស់រាជរដ្ឋាភិបាលជូនប្រជាពលរដ្ឋគ្រប់មូលដ្ឋាន ក្នុងព្រះរាជាណាចក្រកម្ពុជា ដោយធ្វើការទំនាក់ទំនងជាមួយអង្គការសាធារណៈ អង្គការសង្គម អង្គការក្រៅរដ្ឋាភិបាល និងអាជ្ញាធរ គ្រប់ជាន់ថ្នាក់ភូមិភាគ ខេត្ត-ក្រុង

-ចាត់អោយចុះផ្សព្វផ្សាយជាសាធារណៈ នូវលទ្ធផលការងារអធិការកិច្ច ដែលរាជរដ្ឋាភិបាលបានសំរេចរួចហើយនាយកដ្ឋាននេះ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

## ជំពូកទី៥
## អគ្គនាយកដ្ឋានអធិការកិច្ច

មាត្រា ១០ .-

អគ្គនាយកដ្ឋានអធិការកិច្ច មានភារកិច្ចធ្វើជាសេនាធិការអោយក្រសួង លើការងារ :

-គ្រប់គ្រងលើការងារអធិការកិច្ច ។

-ធ្វើរបាយការណ៍តាមការធ្វើអធិការកិច្ចជាក់ស្តែង បញ្ជាក់ពីបញ្ហាទាំងឡាយរបស់បុគ្គល ឬ ស្ថាប័នពាក់ព័ន្ធ ធ្វើការសន្និដ្ឋាន និងលើកសំណូមពរច្បាស់លាស់ជូនរដ្ឋមន្ត្រី ដើម្បីសុំការឯកភាព ធ្វើជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យសំរេច ។

អគ្គនាយកដ្ឋានអធិការកិច្ចដឹកនាំដោយអគ្គនាយកមួយរូប និងមានអគ្គនាយករងមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

អគ្គនាយកដ្ឋានអធិការកិច្ច មាននាយកដ្ឋានចំណុះ ដូចមានចែងក្នុងមាត្រាខាងក្រោម :

មាត្រា ១១ .-

នាយកដ្ឋានទំនាក់ទំនងជាមួយអធិការកិច្ច តាមបណ្តាស្ថាប័ន មានភារកិច្ច :

-ទទួលរាល់សំណុំឯកសារ របាយការណ៍ រួចប្រមូលសរុបលទ្ធផលការងារអធិការកិច្ច របស់អគ្គាធិការដ្ឋាន អធិការដ្ឋាននៅតាមបណ្តាក្រសួង រដ្ឋលេខាធិការដ្ឋាន

-ទំនាក់ទំនង សំរបសំរួល រាល់សកម្មភាពរបស់អគ្គាធិការដ្ឋាន អធិការដ្ឋាន តាមបណ្តាក្រសួង រដ្ឋលេខាធិការដ្ឋាន ដើម្បីជួយអោយការងាររបស់ស្ថាប័នទាំងនោះអោយបានសុក្រឹត្យ

-ពិនិត្យ និងធ្វើអធិការកិច្ចឡើងវិញ នូវលទ្ធផលអធិការកិច្ចនៃអគ្គាធិការដ្ឋាន អធិការដ្ឋាន តាមបណ្តាក្រសួង រដ្ឋលេខាធិការដ្ឋាន ដែលធ្វើរួចហើយ ក្នុងករណីមានការតវ៉ា ឬយល់ឃើញថាមិនត្រឹមត្រូវ

-ចូលរួមសន្និបាតសិក្ខាសាលា នៃអគ្គាធិការដ្ឋាន អធិការដ្ឋាន តាមបណ្តាក្រសួង រដ្ឋលេខាធិការដ្ឋាន

នាយកដ្ឋាននេះដឹកនាំដោយប្រធាន ០១រូប និងមានអនុប្រធានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

មាត្រា ១២ .-

នាយកដ្ឋានអធិការកិច្ច មានភារកិច្ច :

-ធ្វើអធិការកិច្ចលើការពាក់ព័ន្ធ និងចំណូល-ចំណាយ ថវិកាជាតិ នៅតាមក្រសួង រដ្ឋលេខាធិការដ្ឋាន ខេត្ត ក្រុង គ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈ

-ត្រួតពិនិត្យសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ជាទៀងរាល់ឆ្នាំ នៅគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ខេត្ត ក្រុង គ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈ

-ធ្វើអធិការកិច្ចលើករណីដែលពាក់ព័ន្ធ ក្លែងបន្លំ កិបកេងសម្បត្តិរដ្ឋ និងប្រព្រឹត្តអំពើពុករលួយ ធ្វើអោយបាត់បង់ថវិកាជាតិ

-ធ្វើអធិការកិច្ចលើស្ថាប័ននានា ដែលបានទទួលការគ្រប់គ្រង ឬប្រើប្រាស់ជំនួយជាតិ និងអន្តរជាតិ

-ចូលរួមសហការងារអធិការកិច្ច តាមសំណូមពររបស់ស្ថាប័ននានា ។

នាយកដ្ឋាននេះដឹកនាំដោយប្រធាន ០១រូប និងមានអនុប្រធានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

មាត្រា១៣ .-

នាយកដ្ឋាន តាមដានការអនុវត្តន៍ច្បាប់ មានភារកិច្ច :

-តាមដានការអនុវត្តន៍ច្បាប់ ដែលចូលជាធរមានរួចហើយ

-តាមដានការអនុវត្តន៍កម្មវិធីនយោបាយ អនុក្រឹត្យ និង សេចក្តីសំរេចនានារបស់រាជរដ្ឋាភិបាល

-តាមដានការអនុវត្តន៍សេចក្តីសំរេចរបស់រាជរដ្ឋាភិបាល ដែលពាក់ព័ន្ធទៅនឹង សកម្មភាពអធិការកិច្ច

នាយកដ្ឋាននេះ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

មាត្រា១៤ .-

នាយកដ្ឋានទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវ មានភារកិច្ច :

-ពិនិត្យលើបាតុភាពទាក់ទិន ដល់ការងារអធិការកិច្ច ដែលត្រូវបានចុះផ្សាយ ក្នុងសារពត៌មាន ដើម្បីបញ្ជូន តាមសមត្ថកិច្ចពាក់ព័ន្ធ

-ទទួលពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋ និងពីអង្គភាពនានា ហើយធ្វើការសិក្សា ដើម្បីអង្កេតស្រាវជ្រាវ

-ធ្វើកិច្ចសហប្រតិបត្តិការអង្កេត ស្រាវជ្រាវរឿងវិវាទរដ្ឋបាល ដែលស្ថិតនៅក្នុងរង្វង់សមត្ថកិច្ចរបស់រាជរដ្ឋាភិបាល

-អង្កេត ស្រាវជ្រាវ បាតុភាពផ្សេងៗ ដែលក្រសួងប្រគល់អោយ

-អង្កេត ស្រាវជ្រាវ រាល់កិច្ចការ ដែលរាជរដ្ឋាភិបាលប្រគល់អោយ

-អង្កេត ស្រាវជ្រាវ លទ្ធផលរបស់អធិការកិច្ចថ្នាក់ខេត្ត ក្រុង ដែលមានការជំទាស់ ធ្វើពុំទាន់ត្រឹមត្រូវ ដើម្បីធ្វើអង្កេតស្រាវជ្រាវជាថ្មី រួចសន្និដ្ឋាន និងធ្វើសំណើអោយរដ្ឋមន្ត្រីពិនិត្យសំរេច រួចជូនទៅប្រមុខរាជរដ្ឋាភិបាលសំរេច ។

នាយកដ្ឋាននេះ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

មាត្រា១៥ .-

នាយកដ្ឋាន វិវាទកម្ម មានភារកិច្ច :

-ប្រមូលផ្តុំសំណុំរឿង ដើម្បីវិភាគ និងដោះស្រាយជាមួយអង្គភាពពាក់ព័ន្ធ

-រៀបចំប្រមូលសំណុំរឿង ចំពោះករណីដែលត្រូវបញ្ជូនទៅតុលាការ

-ធ្វើការសិក្សាស្រាវជ្រាវ អំពីទំហំនៃការប្រព្រឹត្តិខុសឆ្គងរបស់ស្ថាប័ន គ្រឹះស្ថានសាធារណៈ រដ្ឋបាល សហគ្រាសសាធារណៈ និងអ្នកធ្វើកំហុស រួចធ្វើសន្និដ្ឋាន និងធ្វើសំណើមតិដាក់ជូនរដ្ឋមន្ត្រី ធ្វើការស្នើសុំការសំរេចពីប្រមុខរាជរដ្ឋាភិបាល ។

នាយកដ្ឋាននេះ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

# ជំពូកទី៦

## អគ្គនាយកដ្ឋានរដ្ឋបាលកិច្ចការទូទៅ

មាត្រា១៦ .-

អគ្គនាយកដ្ឋានរដ្ឋបាលកិច្ចការទូទៅ មានភារកិច្ចធ្វើជាលេខាធិការអោយក្រសួង លើការងារ :

-សំរបសំរួល គ្រប់គ្រងការងាររដ្ឋបាល បុគ្គលិក គណនេយ្យ ហិរញ្ញវត្ថុ ផែនការ ស្ថិតិ សំភារៈ បរិក្ខារ និងសារពើភ័ណ្ឌ របស់ក្រសួង

-បូកសរុប លទ្ធផលការងារគ្រប់វិស័យរបស់ក្រសួង ។

អគ្គនាយកដ្ឋានរដ្ឋបាលកិច្ចការទូទៅ ដឹកនាំដោយអគ្គនាយកម្នាក់១រូប និងមានអគ្គនាយករងមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

អគ្គនាយកដ្ឋានរដ្ឋបាលកិច្ចការទូទៅ មាននាយកដ្ឋានចំណុះ ដូចមានចែងក្នុងមាត្រាខាងក្រោម :

មាត្រា១៧ .-

អគ្គនាយកដ្ឋានរដ្ឋបាល បុគ្គលិក មានភារកិច្ច :

-សំរបសំរួលសកម្មភាពការងារគ្រប់ផ្នែក របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

-គ្រប់គ្រង និងចរាចរឯកសារ រដ្ឋបាលផ្សេងៗ របស់ក្រសួង

-ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល និង គ្រប់គ្រងការងារសង្គមកិច្ចរបស់ក្រសួង

-សរុប និងធ្វើរបាយការណ៍ការងារ ប្រចាំសប្តាហ៍ ខែ ត្រីមាស ឆមាស ឆ្នាំ ដែលផ្ញើមកពីអង្គភាពចំណុះ ក្រសួង និង សកម្មភាពផ្សេងៗរបស់ក្រសួង រួចបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី

-គ្រប់គ្រងផ្នែករដ្ឋបាល មន្ត្រីរាជការ និងភ្នាក់ងាររាជការរបស់ក្រសួង ដោយធ្វើទំនាក់ទំនងជាមួយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និង ក្រសួងពាក់ព័ន្ធ

-រៀបចំលិខិតរដ្ឋបាល សំរាប់គ្រប់គ្រងអាជីព មន្ត្រីរាជការរបស់ក្រសួង

-រៀបចំការងារបៀវត្សរ៍ពលកម្ម ប្រាក់កំរៃ និង របបឧបត្ថម្ភសន្តិសុខសង្គម

-រៀបចំតំណែង ឯកទេស និងធនធានមនុស្សរបស់ក្រសួង

-វាយតំលៃតម្រូវការបណ្តុះបណ្តាលបុគ្គលិក

-លើកសំណើដោយផ្ទាល់ ឬតាមសំណូមពររបស់អង្គភាព ក្រោមឱវាទក្រសួង ជូនរដ្ឋមន្ត្រីពិនិត្យសំរេច

-រៀបចំកម្មវិធីបណ្តុះបណ្តាលដំបូង និងបន្តធ្វើទំនាក់ទំនងជាមួយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងអនុវត្ត គោលការណ៍ផ្សេងៗ

-រៀបចំស្ថិតិលើការគ្រប់គ្រងបុគ្គលិក និង តារាងពត៌មានប្រតិបត្តិ ។

* នាយកដ្ឋាននេះ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

មាត្រា១៨ .-

នាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ មានភារកិច្ច ៈ

-ចុះបញ្ជីកាគណនេយ្យជាប្រចាំ

-ត្រួតពិនិត្យបច្ចេកទេស ផែនការប្រតិបត្តិបេឡាកម្មគណនេយ្យរបស់ក្រសួង

-ពត៌មានវិទ្យាសកម្មភាពហិរញ្ញវត្ថុ និងបន្ទុកគណនី

-លើកគំរោងថវិការបស់ក្រសួងប្រចាំឆ្នាំ និង តាមដានការប្រតិបត្តិ

-ប្រមូលផ្តុំ និងសំរបសំរួលជំពូកថវិកា អោយសមស្របតាមគំរោងថវិការដ្ឋ

-តាមដាន រំលឹក ការគ្រប់គ្រងរាល់ការចំណាយរបស់ក្រសួង

-គ្រប់គ្រងបន្ទុកគណនី នូវការអនុវត្តន៍បេឡាកម្មគណនេយ្យ

-គ្រប់គ្រងចំណូល-ចំណាយអោយបានសមស្រប និង បង់ចំណូលចូលថវិការដ្ឋអោយបានតាមការកំណត់ នៃច្បាប់ហិរញ្ញវត្ថុ

-ប្រមូលផ្តុំតម្រូវការ ធ្វើកម្មវិធីចំណាយ គ្រប់គ្រងការរៀបចំផ្គត់ផ្គង់សំភារៈ និងបរិក្ខាររបស់ក្រសួង

-គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសំភារៈ និងធ្វើបញ្ជីសារពើភ័ណ្ឌ

-គ្រប់គ្រងយានដ្ឋាន និងយានយន្តរបស់រដ្ឋ ដែលប្រគល់ជូនក្រសួង ព្រមទាំងធ្វើកម្មវិធីចំណាយ និង បែងចែក ប្រេងឥន្ធនៈ និង គ្រឿងបន្លាស់

-ត្រួតពិនិត្យជាប្រចាំ នូវផែនការផ្គត់ផ្គង់សំភារៈ បរិក្ខារ

-ទទួល និងបែងចែកសំភារៈ បរិក្ខារ ជូនបណ្តាអង្គភាពក្រោមឱវាទក្រសួង

នាយកដ្ឋាននេះ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

## ជំពូកទី៧

## អង្គភាពមូលដ្ឋាន

មាត្រា១៩ .-

នៅតាមខេត្ត ក្រុងនីមួយៗ មានមន្ទីរដែលទាក់ទងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច និងសាខាសមត្ថកិច្ចជំនាញខេត្ត ក្រុង ដែលទទួលបន្ទុកអនុវត្តទិសដៅ និងសំរបសំរួលគ្រប់សកម្មភាពការងារ និងភារកិច្ច របស់ក្រសួង ។

## ជំពូកទី៨

## អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

មាត្រា២០ .-

អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមលក្ខខណ្ឌនៃបទប្បញ្ញត្តិ កំណត់ក្នុងអនុក្រឹត្យលេខ៩១ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិកា ក្នុងបណ្តាក្រសួង ។

## ជំពូកទី៩

## អវសានប្បញ្ញត្តិ

មាត្រា២១ .-

ការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង នៅរដ្ឋបាលកណ្តាល ចាប់ពីថ្នាក់ក្រោមនាយកដ្ឋានចុះ និងមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទំនាក់ទំនង ជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ។

មាត្រា២២ .-

អនុក្រឹត្យលេខ ៩៥ អនក្រ-បក ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអគ្គលេខាធិការដ្ឋានអធិការកិច្ច និង អនុក្រឹត្យលេខ ២០ អនក្រ-បក ចុះថ្ងៃទី២០ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃ អគ្គលេខាធិការដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា ព្រមទាំងបទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា២៣ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា -ព្រឹទ្ធសភា និងអធិការកិច្ច រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួន ។

មាត្រា២៤ .-

អនុក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

★★★

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ៦៧ អនក្រ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ១៩៩៩

អង្គការលេខនៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច



# អនុក្រឹត្យ លេខ ៦៨ អនក្រ/បក
## ស្តីពីការ ផ្ទេរឥណទាន

* * *

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៦៨ ចុះថ្ងៃទី២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម ០២ នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រម ០១ នស/៩៣ ចុះថ្ងៃទី២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រម នស/រកម/០១៩៩/០១ ចុះថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ ១៩៩៨ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៩

-បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី២០ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការបែងចែកឥណទានថវិកាចំណាយតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៩

-បានឃើញអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី២០ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការផ្ទេរចំណូលឥណទានថវិកា សំរាប់ក្រសួងស្ថាប័នថ្មី

-តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សំរេច

**មាត្រា ១** .-ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ៣.០០០ លានរៀល(បីពាន់លានរៀល) ពីជំពូក ៥០ (ចំណាយផ្សេងៗ) នៃខ្ទង់ចំណាយ មិនទាន់បែងចែក មកជំពូក១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច ) របស់ក្រសួងសុខាភិបាល សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៩ ។

**មាត្រា ២** .- ឥណទានថវិកាក្នុងមាត្រា១ខាងលើត្រូវបានអនុញ្ញាតអោយប្រើប្រាស់ សំរាប់បោះពុម្ពផ្សព្វផ្សាយសៀវភៅឯកសារចាំបាច់ បំរើអោយកម្មវិធីជាតិនានា ប្រយុទ្ធនឹងជំងឺរាតត្បាតគ្រប់ប្រភេទ ។

មាត្រា ៣ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួង សុខាភិបាល ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែ សីហា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

បាត់ហត្ថលេខានិងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យ លេខ ៦៩ អនក្រ/បក

## ស្តីពី

## ការផ្តល់ប្រាក់បំណាច់បន្ថែមលើបៀវត្សរ៍ប្រចាំខែសំរាប់អគ្គបញ្ជាការដ្ឋានកងយោធពល ខេមរភូមិន្ទ អគ្គនាយកដ្ឋាននគរបាលជាតិ និង អគ្គនាយកដ្ឋានចំណុះក្រសួងការពារជាតិ

* * *

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០១៩៩/២១ ចុះថ្ងៃទី២៤ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការកែសំរួលរចនាសម្ព័ន្ធចាត់តាំង តួនាទីភារកិច្ចនៃកងយោធពលខេមរភូមិន្ទ

-បានឃើញព្រះរាជក្រឹត្យ នស/រកត/០១៩៩/២២ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងមុខងារអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨៩៤/៥៩ ចុះថ្ងៃទី១៩ ខែ សីហា ឆ្នាំ ១៩៩៤ ស្តីពីការតែងតាំងមុខងារអគ្គនាយកនគរបាលជាតិ

-បានឃើញអនុក្រឹត្យលេខ ៩៤/អនក្រ/តត ចុះថ្ងៃទី២៣ ខែ សីហា ឆ្នាំ ១៩៩៤ ស្តីពីការតែងតាំងមុខងារអគ្គនាយករងនគរបាលជាតិ

-បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីប្រាក់បំណាច់សំរាប់អគ្គសេនាធិការកងយោធពលខេមរភូមិន្ទ និងអគ្គនាយកដ្ឋាននគរបាលជាតិ

-បានឃើញអនុក្រឹត្យលេខ ៣៧ អនក្រ.តត ចុះថ្ងៃទី១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ ស្តីពីការកែសំរួលរចនាសម្ព័ន្ធចាត់តាំងក្រសួងការពារជាតិ

-បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២២ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការកាត់បន្ថយប្រាក់បំណាច់ របស់សមាជិករាជរដ្ឋាភិបាល មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ ចាប់ពីថ្នាក់អនុរដ្ឋលេខាធិការឡើងទៅ

-យោងតាមសភាពការណ៍ និងការងារចាំបាច់របស់កងកម្លាំងប្រដាប់អាវុធជាតិ

សម្រេច

មាត្រា១ .- ត្រូវបានផ្តល់ប្រាក់បំណាច់បន្ថែមលើប្រាក់បៀវត្សប្រចាំខែ សំរាប់អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ អគ្គនាយកដ្ឋាននគរបាលជាតិ និងអគ្គនាយកដ្ឋានចំណុះក្រសួងការពារជាតិ ដូចតទៅ ៖

-ប្រាក់បំណាច់តំណែង
-ប្រាក់បំណាច់បដិសណ្ឋារកិច្ច
-ប្រាក់បំណាច់បេសកកម្ម
-ប្រាក់ឈ្នួលផ្ទះ ទឹក ភ្លើង

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី______ខែ______ឆ្នាំ______

មាត្រា២ .- ប្រាក់បំណាច់បន្ថែមលើប្រាក់បៀវត្សប្រចាំខែ ត្រូវបានកំណត់ដូចមានតារាងខាងក្រោម ៖

| ប្រភេទប្រាក់បំណាច់ មុខតំណែង | ប្រាក់បំណាច់ តំណែង | ប្រាក់បំណាច់ បដិសណ្ឋារកិច្ច | ប្រាក់បំណាច់ បេសកកម្ម | ប្រាក់ឈ្នួល ផ្ទះ ទឹក ភ្លើង | គិតជាប្រាក់ រៀលសរុប |
|---|---|---|---|---|---|
| -អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ស្មើ ទេសរដ្ឋមន្ត្រី | ២៥៩.៣៧៥ | ១៨៦.៨៧៥ | ១១៨.១២៥ | ១៧០.៦២៥ | ៧៣៥.០០០ |
| -អគ្គនាយកនគរបាលជាតិ<br>-អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ<br>-នាយសេនាធិការចំរុះកងយោធពលខេមរភូមិន្ទ<br>-មេបញ្ជាការកងទ័ពជើងគោក<br>ស្មើរដ្ឋមន្ត្រី | ២២៣.១២៥ | ១៧០.៦២៥ | ៨១.៨៧៥ | ១៤៥.៣៧៥ | ៦៣០.០០០ |
| -នាយរង សេនាធិការចំរុះកងយោធពលខេមរភូមិន្ទ<br>-មេបញ្ជាការរងកងទ័ពជើងគោក<br>-អគ្គនាយករងនគរបាលជាតិ<br>-អគ្គនាយកនៃអគ្គនាយកដ្ឋានចំណុះក្រសួងការពារជាតិ<br>ស្មើ រដ្ឋលេខាធិការ<br>-មេបញ្ជាការកងទ័ពជើងទឹក<br>-មេបញ្ជាការកងទ័ពជើងអាកាស<br>-មេបញ្ជាការកងរាជអាវុធហត្ថ<br>-នាយរងសេនាធិការកងទ័ព | ២១០.០០០ | ១៤៥.៣៧៥ | ៧៨.៧៥០ | ៨១.៨៧៥ | ៥២៥.០០០ |

| | | | | | |
|---|---|---|---|---|---|
| ជើងគោក<br>-មេបញ្ជាការយោធភូមិភាគ<br>-អគ្គនាយករងនៃអគ្គនាយកដ្ឋាន<br>ចំណុះក្រសួងការពារជាតិ<br>ស្មើ អនុរដ្ឋលេខាធិការ | ១៥៧.៥០០ | ១០៥.០០០ | ៦៨.៧៥០ | ៦៨.៧៥០ | ៤២០.០០០ |

**មាត្រា៣ .-** ការផ្តល់ប្រាក់បំណាច់បន្ថែមលើបៀវត្សប្រចាំខែ ត្រូវអនុវត្តចាប់ពីខែ សីហា ឆ្នាំ ១៩៩៩ នេះតទៅ ។

**មាត្រា៤ .-** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៥ .-** ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ សីហា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

## អនុក្រឹត្យ លេខ ៧០ អនក្រ/បក

## ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ

## របស់ក្រសួងពត៌មាន

* * *

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រម ០២ នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៤ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងពត៌មាន

-បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន

-បានការឯកភាពរបស់គណៈរដ្ឋមន្ត្រី នាសម័យប្រជុំពេញអង្គថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ១៩៩៩

## សំរេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

អនុក្រឹត្យនេះកំណត់ការរៀបចំអង្គភាពទាំងឡាយនៃក្រសួងព័ត៌មាន និងបេសកកម្មរបស់ក្រសួង មុខការនៃអង្គភាពថ្នាក់ អគ្គនាយកដ្ឋាន នាយកដ្ឋាននានា និងអង្គភាពមូលដ្ឋាននៃព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី២

## បេសកកម្ម និង រចនាសម្ព័ន្ធ

**មាត្រា ២ .-**

ក្រសួងព័ត៌មានត្រូវបានរាជរដ្ឋាភិបាល ប្រគល់ភារកិច្ចអោយដឹកនាំ និងគ្រប់គ្រងលើវិស័យព័ត៌មាន និងសោតទស្សន៍ នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣ .-**

**ក្រសួងព័ត៌មាន មានមុខងារ និង ភារកិច្ច ដូចតទៅ ៖**

-ផ្តល់ព័ត៌មាន និងផ្សព្វផ្សាយតាមរយៈ ជាអាទិ៍ : ព្រឹត្តិប័ត្រ កាសែត ទស្សនាវដ្តី រូបថត វិទ្យុ ទូរទស្សន៍ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានអេឡិចត្រូនិច ......

-អនុញ្ញាតអោយធ្វើអាជីវកម្ម និងគ្រប់គ្រងការប្រើប្រាស់ប៉ុស្តិ៍ផ្សាយ របស់វិទ្យុ ទូរទស្សន៍ លើកលែងតែប្រព័ន្ធ AM និង SW

-សហការជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្នុងការបែងចែកប្រេកង់ដល់ស្ថានីយ៍វិទ្យុ ទូរទស្សន៍

-គ្រប់គ្រងកាសែត ព្រឹត្តិប័ត្រ ទស្សនាវដ្តី និង ការចេញផ្សាយផលិតផលបោះពុម្ព

-គ្រប់គ្រងព័ត៌មាន ដែលផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មាន អេឡិចត្រូនិច

-គ្រប់គ្រងរោងពុម្ព និងសេវាកម្មនានា ដែលទាក់ទងនឹងការចេញផ្សាយ ផលិតផលសោតទស្សន៍

-ផ្តល់អាជ្ញាប័ណ្ណ សំរាប់ការនាំចូល ការនាំចេញ ទស្សនាវដ្តី កាសែត ព្រឹត្តិប័ត្រ .... និងផលិតផលសោតទស្សន៍

-ជួយសំរួលសកម្មភាព អ្នកកាសែតជាតិ អន្តរជាតិ ដែលកំពុងបំពេញការងារនៅកម្ពុជា

-អនុញ្ញាតអោយបង្កើត បញ្ឈប់ ផ្អាកជាបណ្តោះអាសន្ន ការធ្វើអាជីវកម្ម រោងពុម្ព និង សោតទស្សន៍

-ផ្តល់អាជ្ញាប័ណ្ណ ការធ្វើអាជីវកម្ម វិស័យសារព័ត៌មាន

-បណ្តុះបណ្តាល ធ្វើក្រឹតការ វិជ្ជាជីវៈសារព័ត៌មាន

-គាំពារសេរីភាពសារព័ត៌មាន និងកម្មសិទ្ធិបញ្ញា

-បង្កើតការិយាល័យព័ត៌មាន ប្រចាំការនៅក្រៅប្រទេស អង្គការអន្តរជាតិនានា ក្នុងករណីចាំបាច់

-ធ្វើកិច្ចសហប្រតិបត្តិការ ជាមួយអង្គការសារព័ត៌មាន និងសោតទស្សន៍អន្តរជាតិ

-គ្រប់គ្រងរដ្ឋបាល ចាត់តាំង បច្ចេកទេស ហិរញ្ញវត្ថុ និងមូលដ្ឋានសំភារៈរបស់អង្គភាពក្រោមឱវាទ

-ប្រមូលចំណូលអោយបានសមស្រប តាមច្បាប់ហិរញ្ញវត្ថុបង់ចូលថវិការដ្ឋ

-សហការជាមួយក្រសួងពាក់ព័ន្ធ ដើម្បីរៀបចំសេចក្តីព្រាង និង អនុវត្តច្បាប់ ស្តីពីសិទ្ធិចំលង និង សិទ្ធិពាក់ព័ន្ធ ។

មាត្រា ៤ .-

ក្រសួងព័ត៌មាន មានរចនាសម្ព័ន្ធ ដូចតទៅ :

ក ថ្នាក់ដឹកនាំ

១ ខុទ្ទកាល័យ

២ អធិការដ្ឋាន

៣ មជ្ឈមណ្ឌលបណ្តុះបណ្តាល និងស្រាវជ្រាវវិជ្ជាជីវៈសារព័ត៌មាន

៤ អគ្គនាយកដ្ឋាន រដ្ឋបាល សោតទស្សន៍ មាន :

- នាយកដ្ឋានរដ្ឋបាលទូទៅ
- នាយកដ្ឋានបុគ្គលិក
- នាយកដ្ឋានផែនការ គណនេយ្យ ហិរញ្ញកិច្ច
- នាយកដ្ឋានសំភារៈ បរិក្ខារ
- នាយកដ្ឋានអប្បរមព័ត៌មាន
- នាយកដ្ឋានសោតទស្សន៍
- នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ

៥- អគ្គនាយកដ្ឋាន ទីភ្នាក់ងារសារព័ត៌មានកម្ពុជា (AKP) មាន ៖

- នាយកដ្ឋានព័ត៌មាន ក្នុង និងក្រៅប្រទេស
- នាយកដ្ឋានព័ត៌មាន ផ្សាយទៅបរទេស
- នាយកដ្ឋាន កាសែតកម្ពុជា
- នាយកដ្ឋាន ទស្សនាវដ្តី
- នាយកដ្ឋាន រូបថត
- នាយកដ្ឋាន ឯកសារ បណ្ណាល័យ
- នាយកដ្ឋាន បច្ចេកទេស និង បោះពុម្ពផ្សាយ

៦-អគ្គនាយកដ្ឋាន វិទ្យុជាតិកម្ពុជា (RNK) មាន ៖

- នាយកដ្ឋានព័ត៌មានវិទ្យុ ក្នុង និងក្រៅប្រទេស
- នាយកដ្ឋានព័ត៌មានវិទ្យុផ្សាយទៅក្រៅប្រទេស
- នាយកដ្ឋានផលិតកម្មវិធីវិទ្យុ
- នាយកដ្ឋាន បច្ចេកទេសវិទ្យុ

៧ អគ្គនាយកដ្ឋាន ទូរទស្សន៍ជាតិកម្ពុជា (TVK) មាន ៖

- នាយកដ្ឋានព័ត៌មានទូរទស្សន៍ ក្នុង និងក្រៅប្រទេស

- នាយកដ្ឋានរដ្ឋបាល ហិរញ្ញវត្ថុ និងបុគ្គលិក

- នាយកដ្ឋានផលិតកម្មវិធីទូរទស្សន៍

- នាយកដ្ឋាន បច្ចេកទេសទូរទស្សន៍

ខ - ភ្នាក់ងាររដ្ឋ

អង្គភាពព័ត៌មាន ទាំងបួន - ជាអង្គភាពសាធារណៈរដ្ឋបាលរបស់ក្រសួង

អង្គភាពទាំង ៣ របស់ក្រសួងព័ត៌មាន ក្រោមការគ្រប់គ្រងរបស់ក្រសួង និងរបស់អគ្គនាយកដ្ឋាន AKP, RNK-TVK ដែលមានចែងក្នុងមាត្រា ១-២-៣-៤-៥ នៃអនុក្រឹត្យនេះ ។

## ជំពូកទី ៣

## ខុទ្ទកាល័យ

មាត្រា ៥ .-

ខុទ្ទកាល័យរដ្ឋមន្ត្រី មានភារកិច្ចអនុវត្តតាមគោលការណ៍ ដែលបានកំណត់ដោយបទបញ្ញត្តិ នៃអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន ។

## ជំពូកទី៤

## អធិការដ្ឋាន

មាត្រា ៦ .-

អធិការដ្ឋាន របស់ក្រសួងព័ត៌មាន មានភារកិច្ចជាសេនាធិការអោយក្រសួងក្នុងការងារ ៖

-ធ្វើអធិការកិច្ចជាប្រចាំ នៅលើគ្រប់អង្គភាពក្រោមឱវាទក្រសួង

-ធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រី ពីការប្រព្រឹត្តទៅរបស់អង្គភាពដែលបានធ្វើអធិការកិច្ចរួចហើយ និងពីអធ្យាបាយកែលំអការប្រព្រឹត្តទៅរបស់អង្គភាពទាំងនោះ

-ប្រតិបត្តិភារកិច្ច តាមការដែលរដ្ឋមន្ត្រីប្រគល់ជូន

អធិការដ្ឋានដឹកនាំដោយ អធិការបម្រើ១រូប មានឋានៈស្មើប្រធាននាយកដ្ឋាន អមដោយអធិការរង មានឋានៈស្មើអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

## ជំពូកទី៥

## មណ្ឌលបណ្តុះបណ្តាល និង វិក្រឹតការវិជ្ជាជីវៈសារព័ត៌មាន

មាត្រា ៧ .-

មណ្ឌលបណ្តុះបណ្តាល និង វិក្រឹតការវិជ្ជាជីវៈសារព័ត៌មាន មានភារកិច្ចជាសេនាធិការអោយក្រសួងក្នុងការងារ ៖

-បណ្តុះបណ្តាលធនធានមនុស្ស ខាងវិស័យព័ត៌មាន និង សោតទស្សន៍

-សហប្រតិបត្តិការជាមួយអង្គការអន្តរជាតិនានា ដើម្បីអភិវឌ្ឍលើកកម្ពស់វិជ្ជាជីវៈសារព័ត៌មាន នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

-អនុវត្តក្រមសីលធម៌អ្នកសារព័ត៌មាន និង វិក្រឹតការវិជ្ជាជីវៈសារព័ត៌មាន ដឹកនាំដោយនាយកមួយរូប មានឋានៈស្មើប្រធាននាយកដ្ឋានអមដោយនាយករង មានឋានៈស្មើអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

## ជំពូកទី៦

## អគ្គនាយកដ្ឋានរដ្ឋបាល សោតទស្សន៍

**មាត្រា ៨ .-**

**អគ្គនាយកដ្ឋានរដ្ឋបាល សោតទស្សន៍ មានភារកិច្ចជាសេនាធិការ ដោយទទួលខុសត្រូវការ ៖**

អនុវត្តមាត្រា ៣ លើកលែងតែវាក្យខណ្ឌទី១ នៃអនុក្រឹត្យនេះ ។

-អគ្គនាយកដ្ឋានរដ្ឋបាល សោតទស្សន៍ ដឹកនាំដោយអគ្គនាយក១រូប អមដោយអគ្គនាយករងមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

-អគ្គនាយកដ្ឋានរដ្ឋបាល សោតទស្សន៍ មាននាយកដ្ឋានចំនួន៧ ដូចមានចែងក្នុងមាត្រា ៩-១០-១១-១២-១៣-១៤-១៥

**មាត្រា ៩ .-**

**នាយកដ្ឋានរដ្ឋបាលទូទៅ មានភារកិច្ច ៖**

-សំរបសំរួល និងដោះស្រាយការងារជូនគ្រប់អង្គភាព នៅថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន ក្រោមឱវាទក្រសួង ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល

-គ្រប់គ្រងត្រារបស់ក្រសួង

-សារាចរ និង គ្រប់គ្រងលិខិត ឯកសាររដ្ឋបាលទាំងអស់របស់ក្រសួង

-ប្រមូលសរុប និង ធ្វើរបាយការណ៍ការងារ សកម្មភាពផ្សេងៗរបស់ក្រសួង

-រក្សាសណ្តាប់ធ្នាប់ និង សុវត្ថិភាពក្នុងក្រសួង

-ចងក្រង និងថែរក្សា ឯកសារតម្កល់របស់ក្រសួង

-អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់អោយ ។

នាយកដ្ឋានរដ្ឋបាលទូទៅ ដឹកនាំដោយនាយក១រូប មានឋានៈស្មើប្រធាននាយកដ្ឋាន អមដោយនាយករង មានឋានៈស្មើអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

**មាត្រា ១០ .-**

**នាយកដ្ឋានបុគ្គលិក មានភារកិច្ច ៖**

-រៀបចំសំណុំឯកសារ សំរាប់ការគ្រប់គ្រងអាជីពរបស់មន្ត្រីរាជការ ជាអាទិ ការតាំងស៊ប់ ផ្ទេរ ផ្លាស់ប្តូរកន្លែងធ្វើការ តម្លើងថ្នាក់ ឋានន្តរស័ក្តិ លើកសរសើរ ដាក់វិន័យ ការដាក់អោយនៅក្រៅក្របខណ្ឌ ដាក់

អោយស្ថិតក្នុងតាមលំដាប់ថ្នាក់បុគ្គលិក មុខតំណែងក្របខ័ណ្ឌ ក្រសួង សម្របសម្រួលរៀបចំការចូល និវត្តន៍ បាត់បង់សម្បទាវិជ្ជាជីវៈ

-គ្រប់គ្រង និង រៀបចំវិធីបណ្តុះបណ្តាល ធនធានមនុស្សរបស់ក្រសួង

-គ្រប់គ្រងសំណុំលិខិតមន្ត្រីរាជការក្រសួង

-ចេញវិញ្ញាបនប័ត្របន្ទុកគ្រួសារ លិខិតបញ្ជាបេសកកម្ម ប័ណ្ណការធ្វើដំណើរ លិខិតឈប់សំរាក និងលិខិតអនុញ្ញាតច្បាប់

-រៀបចំតារាងប្រវត្តិ និងត្រួតពិនិត្យតារាងប្រវត្តិរូបមន្ត្រីរាជការ

-អនុវត្តការកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់អោយ ។

-នាយកដ្ឋានបុគ្គលិក ដឹកនាំដោយនាយក១រូប មានឋានៈស្មើប្រធាននាយកដ្ឋាន អមដោយនាយករង មានឋានៈស្មើអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

មាត្រា ១១ .-

នាយកដ្ឋានផែនការ គណនេយ្យ ហិរញ្ញកិច្ច មានភារកិច្ច ៖

-លើកគំរោងផែនការអភិវឌ្ឍន៍ ផែនការចំណូល ចំណាយថវិកាក្រសួង

-តាមដានការប្រតិបត្តិថវិកាអោយបាន តាមច្បាប់ហិរញ្ញវត្ថុ

-ប្រមូលផ្តុំ និង សំរបសំរួលជំពូកថវិកា

-ប្រមូលផ្តុំ និង សំរបសំរួលរាល់ការចំណាយរបស់ក្រសួង បូកសរុបការចំណាយថវិកា ត្រួតពិនិត្យសំណុំឯកសារ នៃការចំណាយពីគ្រប់អង្គភាពចំណុះ

-តាមដាន រំលើកការគ្រប់គ្រងគណនីពិសេស

-គ្រប់គ្រងបន្ទុកគណនីនៃការអនុវត្តន៍សេវាកម្មសាធារណៈ

នាយកដ្ឋានផែនការ គណនេយ្យ ហិរញ្ញកិច្ច ដឹកនាំដោយនាយក១រូប មានឋានៈស្មើប្រធាននាយកដ្ឋាន អមដោយនាយករង មានឋានៈស្មើអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

មាត្រា ១២ .-

នាយកដ្ឋានសំភារៈ បរិក្ខារ មានភារកិច្ច ៖

-ប្រមូលផ្តុំ តំរូវការ ធ្វើកម្មវិធីចំណាយ គ្រប់គ្រង បែងចែកសំភារៈនិង បរិក្ខាររបស់ក្រសួង

-គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសំភារៈ និងបញ្ជីសារពើភ័ណ្ឌ របស់ក្រសួង

-លើកគំរោងផែនការសាងសង់ ជួសជុល ផ្គត់ផ្គង់ និង ថែរក្សា

-ត្រួតពិនិត្យ បច្ចេកទេសនៃការប្រតិបត្តិសេវាកម្ម សាធារណៈ ។

នាយកដ្ឋានសំភារៈ បរិក្ខារ ដឹកនាំដោយនាយក១រូប មានឋានៈស្មើប្រធាននាយកដ្ឋាន អមដោយនាយករង មានឋានៈស្មើអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

មាត្រា ១៣ .-

នាយកដ្ឋានសោតទស្សន៍ មានភារកិច្ច ៖

-គ្រប់គ្រង ស្ថានីយវិទ្យុ ទូរទស្សន៍ ឯកជន

-គ្រប់គ្រងរោងពុម្ព ត្រួតពិនិត្យការបោះពុម្ពផ្សាយ និងការចេញផ្សាយ ផលិតផលបោះពុម្ព

-ត្រួតពិនិត្យការនាំចូល នាំចេញផលិតផលបោះពុម្ពគ្រប់ប្រភេទ

-ត្រួតពិនិត្យការនាំចូល នាំចេញផលិតផលទស្សនីយកម្ម វីដេអូ ឌីស្កអាត់ កាសែត គ្រប់ប្រភេទ....

-គ្រប់គ្រងការផ្សព្វផ្សាយ អាហ្វីស ប៉ាណូ ពីឡូប្រ៊ុស្ស៊ុល ផ្ទាំងផ្សព្វ... តាមទីសាធារណៈ ដែលជាការ មានលក្ខណៈជាការអបអរសាទរ និង ផ្សព្វផ្សាយពាណិជ្ជកម្ម ។

-អនុញ្ញាតបើក និង បញ្ឈប់សកម្មភាពអាជីវកម្ម រោងពុម្ព ស្ថានីយវិទ្យុ ទូរទស្សន៍ និងអង្គភាពសារព័ត៌មាន ទាំងឡាយ ដែលពាក់ព័ន្ធការបោះពុម្ពផ្សាយ និងសោតទស្សន៍ ។

នាយកដ្ឋានសោតទស្សន៍ ដឹកនាំដោយនាយក១រូប មានឋានៈស្មើប្រធាននាយកដ្ឋាន អមដោយនាយក រង មានឋានៈស្មើអនុប្រធាននាយកដ្ឋានមួយចំនួន តាមតម្រូវការភារកិច្ចជាក់ស្ដែង .

**មាត្រា ១៤ .-**

**នាយកដ្ឋានមជ្ឈមណ្ឌលព័ត៌មាន មានភារកិច្ច ៖**

-ប្រមូល និង ផ្ដល់ព័ត៌មាន ស្ថិតិសង្ខេបព័ត៌មាន កិច្ចសហការនៃក្រសួង ....

-ចុះបញ្ជីកាសែត ព្រឹត្តិប័ត្រ ទស្សនាវដ្ដីក្នុងស្រុក និងបរទេសដែលមកបើកការិយាល័យនៅកម្ពុជា

-ធ្វើការឆ្លើយតប ចំពោះសារព័ត៌មានក្នុងស្រុក និងអន្តរជាតិ

-ផ្ដល់ប័ណ្ណព័ត៌មាន ជូនអ្នកសារព័ត៌មានក្នុងស្រុក និងអន្តរជាតិ

-ផ្ដល់អាជ្ញាប័ណ្ណអោយធ្វើអាជីវកម្ម សារព័ត៌មាន ទស្សនាវដ្ដី ព្រឹត្តិប័ត្រ ព័ត៌មានក្នុងស្រុក និង អន្តរជាតិ ។

នាយកដ្ឋានមជ្ឈមណ្ឌលព័ត៌មាន ដឹកនាំដោយនាយក១រូប មានឋានៈស្មើប្រធាននាយកដ្ឋាន អមដោយនាយក រង មានឋានៈស្មើអនុប្រធាននាយកដ្ឋានមួយចំនួន តាមតម្រូវការភារកិច្ចជាក់ស្ដែង ។

**មាត្រា ១៥ .-**

**នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ មានភារកិច្ច ៖**

-រៀបចំកិច្ចព្រមព្រៀង ពិធីសារ សហប្រតិបត្តិការនានា ជាមួយបរទេស

-ពិនិត្យ តាមដាន វាយតម្លៃការអនុវត្តន៍ កិច្ចសហប្រតិបត្តិការនានា

-រៀបចំកម្មវិធី និងផែនការ សំរាប់គណៈប្រតិភូជាតិ អន្តរជាតិ ចេញ និង ចូល ធ្វើទស្សនកិច្ចរបស់ ក្រសួង រៀបចំ ពាក់ព័ន្ធ ពិធីការជាផ្លូវការ របស់ក្រសួង ។

នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ដឹកនាំដោយនាយក១រូប មានឋានៈស្មើប្រធាននាយកដ្ឋាន អមដោយ នាយករង មានឋានៈស្មើអនុប្រធាននាយកដ្ឋានមួយចំនួន តាមតម្រូវការភារកិច្ចជាក់ស្ដែង ។

## ជំពូកទី៧

## អគ្គនាយកដ្ឋានទីភ្នាក់ងារសារព័ត៌មានកម្ពុជា (AKP)

**មាត្រា ១៦ .-**

អគ្គនាយកដ្ឋានទីភ្នាក់ងារសារព័ត៌មានកម្ពុជាអក្សរកាត់ (AKP) មានភារកិច្ចជាសេនាធិការអោយក្រសួងក្នុងការងារ ៖

-ផ្សព្វផ្សាយព័ត៌មានប្រចាំថ្ងៃ ជាភាសាជាតិ អន្តរជាតិ នៅក្នុង និងនៅក្រៅប្រទេស តាមរយៈ ព្រឹត្តិប័ត្រព័ត៌មាន ទស្សនាវដ្តី រូបថត សៀវភៅ អាល់ប៊ុម ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានអេឡិចត្រូនិច ....

-ប្រមូលព័ត៌មានពីក្នុង និងក្រៅប្រទេស តាមគ្រប់មធ្យោបាយ

-ពិនិត្យកែសម្រួល ចាត់ចែងការផលិត ការផ្សព្វផ្សាយ និងរក្សាទុកឯកសារ

-គ្រប់គ្រង អភិវឌ្ឍន៍ធនធានមនុស្ស បច្ចេកទេស ថវិកា សម្ភារៈ និងហេដ្ឋារចនាសម្ព័ន្ធ របស់ទីភ្នាក់ងារ AKP នៅថ្នាក់កណ្តាល និងការិយាល័យតំណាងទីភ្នាក់ងារ AKP

-ធ្វើទំនាក់ទំនងសហប្រតិបត្តិការជាមួយទីភ្នាក់ងារ និងអង្គការព័ត៌មានអន្តរជាតិនានា ។

អគ្គនាយកដ្ឋានទីភ្នាក់ងារសារព័ត៌មានកម្ពុជា ដឹកនាំដោយអគ្គនាយកមួយរូប អមដោយអគ្គនាយករងមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

អគ្គនាយកដ្ឋានទីភ្នាក់ងារសារព័ត៌មានកម្ពុជា មាននាយកដ្ឋានចំនួន៧ ដូចមានចែងក្នុងមាត្រា១៧-១៨-១៩-២០-២១-២២-២៣ ។

**មាត្រា ១៧.-**

**នាយកដ្ឋានព័ត៌មាន ក្នុង និងក្រៅប្រទេស មានភារកិច្ច ៖**

-ចុះប្រមូលព័ត៌មានគ្រប់ទិសទី ទូទាំងព្រះរាជាណាចក្រកម្ពុជា

-ប្រមូលព័ត៌មានពីក្រៅប្រទេស តាមគ្រប់មធ្យោបាយ

-ពិនិត្យ ចងក្រង ជំរើស អត្ថបទគ្រប់ប្រភេទ

-ចេញផ្សាយជាភាសាជាតិ អំពីព័ត៌មាន ក្នុង និងក្រៅប្រទេសប្រចាំថ្ងៃ តាមរយៈព្រឹត្តិប័ត្រអាន និង ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានអេឡិចត្រូនិច នៅក្នុង និងនៅក្រៅប្រទេស ។

នាយកដ្ឋានព័ត៌មានក្នុង និង ក្រៅប្រទេស ដឹកនាំដោយនាយកម្នាក់ អមដោយនាយករង អនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

**មាត្រា ១៨ .-**

**នាយកដ្ឋានព័ត៌មាន ផ្សាយទៅបរទេស មានភារកិច្ច ៖**

-ចុះប្រមូលព័ត៌មានគ្រប់ទិសទី ទូទាំងព្រះរាជាណាចក្រកម្ពុជា

-ពិនិត្យ ចងក្រង ជំរើស អត្ថបទ គ្រប់ប្រភេទ

-ចេញផ្សាយព័ត៌មានប្រចាំថ្ងៃ ជាភាសាបរទេស តាមរយៈ ព្រឹត្តិប័ត្រ និង ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានអេឡិចត្រូនិច នៅក្នុង និងនៅក្រៅប្រទេស ។

នាយកដ្ឋានពត៌មានផ្សាយទៅបរទេស ដឹកនាំដោយនាយក១រូប មានឋានៈស្មើ ប្រធាននាយកដ្ឋាន អមដោយនាយករង មានឋានៈស្មើអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

មាត្រា ១៩ .-

**នាយកដ្ឋាន កាសែតកម្ពុជា មានភារកិច្ច ៖**

-ចុះប្រមូលពត៌មានគ្រប់វិស័យ ទូទាំងព្រះរាជាណាចក្រកម្ពុជា

-និពន្ធ ចងក្រង កែលំអ អត្ថបទ គ្រប់ប្រភេទ

-ចេញផ្សាយកាសែតកម្ពុជា ជាភាសាជាតិ និងភាសាបរទេស នៅក្នុង និងទៅក្រៅប្រទេស ។

-ផ្សព្វផ្សាយសេចក្តីសម្រេចចិត្ត សេចក្តីណែនាំ គោលការណ៍ អនុក្រឹត្យ ច្បាប់ និង សេចក្តីប្រកាសពត៌មានទាំងឡាយ របស់រាជរដ្ឋាភិបាលកម្ពុជា អោយប្រជាពលរដ្ឋបានជ្រួតជ្រាប

-និពន្ធអត្ថបទដែលឆ្លុះបញ្ចាំងអំពីមាគ៌ានយោបាយ របស់រាជរដ្ឋាភិបាល

-ផ្សព្វផ្សាយពីបំណងប្រាថ្នា របស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ក្នុងការរួមចំណែកកសាង និងការពារជាតិ។

នាយកដ្ឋានកាសែតកម្ពុជា ដឹកនាំដោយនាយក១រូប មានឋានៈស្មើ ប្រធាននាយកដ្ឋាន អមដោយនាយករង មានឋានៈស្មើអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

មាត្រា ២០ .-

**នាយកដ្ឋាន ទស្សនាវដ្តី មានភារកិច្ច ៖**

-ចុះយកពត៌មាន ថតរូបលើគ្រប់វិស័យ ទូទាំងព្រះរាជាណាចក្រកម្ពុជា

-ចេញផ្សាយទស្សនាវដ្តី សៀវភៅរូបថត ជាភាសាជាតិ និងភាសាបរទេស នៅក្នុងនិងទៅក្រៅប្រទេស

-ផលិតផ្ទាំងរូបភាព ប្រតិទិន ព្រមទាំងប័ណ្ណប៉ុស្តាល់ផ្សេងៗ..... ។

នាយកដ្ឋាន ទស្សនាវដ្តី ដឹកនាំដោយនាយក១រូប មានឋានៈស្មើ ប្រធាននាយកដ្ឋាន អមដោយនាយករង មានឋានៈស្មើអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

មាត្រា ២១ .-

**នាយកដ្ឋាន ថតរូប មានភារកិច្ច ៖**

-ចុះយកពត៌មានរូបថត លើគ្រប់វិស័យ ទូទាំងព្រះរាជាណាចក្រកម្ពុជា

-ផលិត និងចេញផ្សាយរូបថត គ្រប់វិស័យ នៅក្នុង និងទៅក្រៅប្រទេស ។

-ចងក្រង រក្សាការ ហ្វីលរូបថត

-ផ្លាស់ប្តូររូបថត ជាមួយទីភ្នាក់ងារ និងអង្គការពត៌មាននានាលើសកលលោក ។

នាយកដ្ឋានរូបថត ដឹកនាំដោយនាយក១រូប មានឋានៈស្មើ ប្រធាននាយកដ្ឋាន អមដោយនាយករង មានឋានៈស្មើអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

មាត្រា ២២ .-

**នាយកដ្ឋាន បច្ចេកទេស និងបោះពុម្ពផ្សាយ មានភារកិច្ច ៖**

-ទទួល និងផ្សាយប្រចាំថ្ងៃនូវដំណឹងរូបថត ជាមួយទីភ្នាក់ងារ និងអង្គការពត៌មាននានាលើសកលលោក តាមមធ្យោបាយទូរគមនាគមន៍ទំនើប

-គ្រប់គ្រង ស្តុកក្រដាសម្ហូបគ្រឿងសំភារៈបច្ចេកទេស របស់ទីភ្នាក់ងារ AKP

-សិក្សាស្រាវជ្រាវ ពីបច្ចេកទេសលើកកំពស់ការកែលំអ បំពាក់សំភារៈបច្ចេកទេសថ្មី តាមតម្រូវការការ រីកចំរើនរបស់ទីភ្នាក់ងារសារព័ត៌មានជាតិ នាពេលអនាគត

-គ្រប់គ្រងរោងពុម្ពរបស់ទីភ្នាក់ងារ AKP ។

នាយកដ្ឋាន បច្ចេកទេស និងបោះពុម្ពផ្សាយ ដឹកនាំដោយនាយក១រូប មានឋានៈស្មើប្រធាននាយកដ្ឋាន អមដោយនាយករង មានឋានៈស្មើអនុប្រធាននាយកដ្ឋានមួយចំនួន ជាចំនួនតាមការចាំបាច់ ។

មាត្រា ២៣ .-

**នាយកដ្ឋាន ឯកសារ បណ្ណាល័យ មានភារកិច្ច ៖**

-ប្រមូល ពិនិត្យភាគជាតិ និងភាគបរទេស ចំណាត់ និងរក្សាឯកសារគ្រប់ប្រភេទ និង គ្រប់វិស័យ សំរាប់ស្រាវជ្រាវ ។

-ទំនាក់ទំនងជាមួយបណ្ណាល័យស្រាវជ្រាវជាតិ អន្តរជាតិ អង្គការសារព័ត៌មាននានា ក្រសួង ស្ថាប័ន អង្គ ខេត្ត ក្រុង មូលដ្ឋាន ដើម្បីទិញ ផ្លាស់ប្តូរឯកសារ ។

-តម្កល់ទុកឯកសារផ្សេងៗ បំរើអោយការស្រាវជ្រាវ ។

-គ្រប់គ្រងបណ្ណាល័យ របស់ទីភ្នាក់ងារ AKP ។

នាយកដ្ឋានឯកសារ បណ្ណាល័យ ដឹកនាំដោយនាយក១រូប មានឋានៈស្មើ ប្រធាននាយកដ្ឋាន អមដោយនាយករង មានឋានៈស្មើអនុប្រធាននាយកដ្ឋានមួយចំនួន ជាចំនួនតាមការចាំបាច់ ។

## ជំពូកទី ៨

## អគ្គនាយកដ្ឋាន វិទ្យុជាតិកម្ពុជា (RNK)

មាត្រា ២៤ .-

**អគ្គនាយកដ្ឋាន វិទ្យុជាតិកម្ពុជា អក្សរកាត់ (RNK) មានភារកិច្ច ជាសេនាធិការអោយ ក្រសួងក្នុងការងារ ៖**

-ផ្សព្វផ្សាយប្រចាំថ្ងៃ នូវព័ត៌មានតាមវិទ្យុ ជាភាគជាតិ ភាគបរទេស និង កម្មវិធីសិល្បៈ វប្បធម៌ តន្ត្រីសម័យ បុរាណ ដែលបំរើអោយការកំសាន្ត ការអប់រំ ការកំសាន្តរបស់ប្រជាជននៅក្នុង និងក្រៅប្រទេស តាមរលកធាតុអាកាស AM FM និង SW ។

-លើកគំរោងផែនការ ថវិកា ដើម្បីពង្រីកការងារវិទ្យុជាតិកម្ពុជា ។

-ធ្វើកិច្ចសហប្រតិបត្តិការ ជាមួយអង្គការព័ត៌មានអន្តរជាតិ និងវិទ្យុបរទេសនានា ។

អគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជា ដឹកនាំដោយអគ្គនាយក១រូប អមដោយអគ្គនាយករងមួយចំនួន ជាចំនួនតាមការចាំបាច់ ។

អគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជា មាននាយកដ្ឋានចំនួន៤ ដូចមានចែងក្នុងមាត្រា ២៥-២៦-២៧-២៨

មាត្រា ២៥ .-

នាយកដ្ឋាន ព័ត៌មាន វិទ្យុ ក្នុង និងក្រៅប្រទេស មានភារកិច្ច ៖

-ផលិតព័ត៌មាន និពន្ធ និងផ្សព្វផ្សាយព័ត៌មានប្រចាំថ្ងៃ ពីគ្រប់ទិសទី

-ជ្រើសរើសអត្ថបទព័ត៌មានពីភ្នាក់ងារព័ត៌មានពិភពលោក អង្គការព័ត៌មានទូទាំងប្រទេស ដូចជា AKP កាសែតព័ត៌មាន ទស្សនាវដ្តី វិទ្យុ ទូរទស្សន៍នានា....

-និពន្ធអត្ថបទគ្រប់ប្រភេទ ដែលទាក់ទងនឹងកម្មវិធី សម្រាប់ផ្សាយតាមកាលវិភាគ ។ល។

នាយកដ្ឋានព័ត៌មានវិទ្យុ ក្នុង និងក្រៅប្រទេស ដឹកនាំដោយនាយកម្នាក់ មានឋានៈស្មើប្រធាននាយកដ្ឋាន និងនាយករង មានឋានៈស្មើអនុប្រធាននាយកដ្ឋានមួយចំនួន ជាចំនួនកំណត់តាមការចាំបាច់ ។

មាត្រា ២៦ .-

នាយកដ្ឋាន ព័ត៌មាន វិទ្យុ ផ្សាយទៅបរទេស មានភារកិច្ច ៖

-ចុះយកព័ត៌មាន និពន្ធ បកប្រែ កែលំអ អត្ថបទគ្រប់ប្រភេទ ជាភាសាបរទេស ជាអាទិ៍ ភាសាអង់គ្លេស បារាំង វៀតណាម ថៃ ឡាវ ដើម្បីផ្សព្វផ្សាយប្រចាំថ្ងៃ នៅក្នុង និងក្រៅប្រទេស ។

នាយកដ្ឋានព័ត៌មានវិទ្យុ ផ្សាយទៅបរទេស ដឹកនាំដោយនាយកម្នាក់ មានឋានៈស្មើប្រធាននាយកដ្ឋាន និងនាយករង មានឋានៈស្មើអនុប្រធាននាយកដ្ឋានមួយចំនួន ជាចំនួនកំណត់តាម ការចាំបាច់ ។

មាត្រា ២៧ .-

នាយកដ្ឋាន ផលិតកម្មវិធី វិទ្យុ មានភារកិច្ច ៖

-គ្រប់គ្រង និងរៀបចំផែនការកម្មវិធីផ្សាយរបស់វិទ្យុ

-ផលិត សហការផលិតកម្មវិធីផ្សព្វផ្សាយគ្រប់ប្រភេទ

នាយកដ្ឋានផលិត កម្មវិធីវិទ្យុ ដឹកនាំដោយនាយកម្នាក់ មានឋានៈស្មើប្រធាន នាយកដ្ឋាន និងនាយករង មានឋានៈស្មើអនុប្រធាននាយកដ្ឋានមួយចំនួន ជាចំនួនកំណត់តាម ការចាំបាច់ ។

មាត្រា ២៨ .-

នាយកដ្ឋាន បច្ចេកទេស វិទ្យុ មានភារកិច្ច ៖

-ធានាការផ្សាយរបស់វិទ្យុ

-គ្រប់គ្រងវិស័យបច្ចេកទេស គុណភាព នៃការផ្សាយរបស់វិទ្យុ

-សិក្សាស្រាវជ្រាវ បច្ចេកទេស លើកកំពស់អភិវឌ្ឍន៍មូលដ្ឋានបច្ចេកទេស របស់វិទ្យុជាតិកម្ពុជា ។

នាយកដ្ឋានបច្ចេកទេសវិទ្យុ ដឹកនាំដោយនាយកម្នាក់ មានឋានៈស្មើប្រធាននាយកដ្ឋាន និងនាយករង មានឋានៈស្មើអនុប្រធាននាយកដ្ឋានមួយចំនួន ជាចំនួនកំណត់តាមការចាំបាច់ ។

## ជំពូកទី៩

## អគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា (ទទក) (TVK)

មាត្រា ២៩ .-

អគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា ហៅកាត់ (ទទក) (TVK) មានភារកិច្ច ជា សេនាធិការអោយក្រសួងក្នុងការងារ ៖

-ផ្សព្វផ្សាយប្រចាំថ្ងៃ នូវពត៌មានរូបភាព តាមទូរទស្សន៍ជាភាសាជាតិ អន្តរជាតិ និង កម្មវិធីសិល្បៈ វប្បធម៌ តន្ត្រីកំសាន្ត ល្ខោន ដែលបំរើអោយការយល់ដឹង ការអប់រំ ការកំសាន្តសប្បាយ នៅក្នុង និងទៅក្រៅប្រទេស តាមរលកធាតុអាកាស

-រៀបចំរោងផែនការ ថវិកា ដើម្បីដំណើរការរបស់ទូរទស្សន៍ជាតិកម្ពុជា

-ធ្វើកិច្ចសហប្រតិបត្តិការ ជាមួយអង្គការពត៌មានអន្តរជាតិ និងទូរទស្សន៍បរទេស ។

អគ្គនាយកដ្ឋាន ទូរទស្សន៍ជាតិកម្ពុជា ដឹកនាំដោយអគ្គនាយក១រូប អមដោយអគ្គនាយករងមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

អគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា មាននាយកដ្ឋានចំនួន៤ ដូចមានចែងក្នុងមាត្រា៣០-៣១-៣២-៣៣

មាត្រា ៣០ .-

នាយកដ្ឋានពត៌មាន ទូរទស្សន៍ ក្នុង និងក្រៅប្រទេស មានភារកិច្ច ៖

-យកពត៌មាន និពន្ធ និងផ្សព្វផ្សាយរូបភាពប្រចាំថ្ងៃតាមទូរទស្សន៍ ជាភាសាជាតិ

-ជ្រើសរើសអត្ថបទអាំងឡាយ ដែលបានមកពីប្រភពអង្គការពត៌មានផ្សេងៗ ដូចជា AKP សារពត៌មាន ទស្សនាវដ្តី វិទ្យុ ទូរទស្សន៍ បរទេស .....

-និពន្ធអត្ថបទគ្រប់ប្រភេទ ដែលបំរើអោយកម្មវិធីនយោបាយ របស់រាជរដ្ឋាភិបាល ។

នាយកដ្ឋាន ពត៌មាន ទូរទស្សន៍ ក្នុង និង ក្រៅប្រទេស ដឹកនាំដោយនាយក១រូប មានឋានៈស្មើ ប្រធាននាយកដ្ឋាន អមដោយនាយករង មានឋានៈស្មើអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

មាត្រា ៣១ .-

នាយកដ្ឋានពត៌មាន ទូរទស្សន៍ ផ្សាយទៅបរទេស មានភារកិច្ច ៖

-ចុះយកពត៌មាន រូបភាព បកប្រែដំណើង អត្ថបទគ្រប់ប្រភេទ ជាភាសាបរទេស ដើម្បីផ្សព្វផ្សាយ ប្រចាំថ្ងៃ នៅក្នុង និងទៅក្រៅប្រទេស

នាយកដ្ឋានពត៌មាន ទូរទស្សន៍ ផ្សាយទៅបរទេស ដឹកនាំដោយនាយក១រូប មានឋានៈស្មើប្រធាន នាយកដ្ឋាន អមដោយនាយករង មានឋានៈស្មើអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការតាមការ ចាំបាច់ ។

**មាត្រា ៣២ .-**

**នាយកដ្ឋានផលិតកម្មវិធី ទូរទស្សន៍ មានភារកិច្ច ៖**

-គ្រប់គ្រង និងរៀបចំផែនការ កម្មវិធីផ្សាយរបស់ទូរទស្សន៍

-ផលិត សហការផលិត កម្មវិធីផ្សាយ គ្រប់ប្រភេទ

-ស្រាវជ្រាវ ស្ទាបស្ទង់ សាធារណមតិ ទូរទស្សនិកជន អំពីកម្មវិធីផ្សាយរបស់ទូរទស្សន៍ជាតិកម្ពុជា ។

នាយកដ្ឋានផលិតកម្មវិធីទូរទស្សន៍ ដឹកនាំដោយនាយក១រូប មានឋានៈស្មើប្រធាននាយកដ្ឋាន អមដោយនាយករង មានឋានៈស្មើអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ៣៣ .-**

**នាយកដ្ឋាន បច្ចេកទេស ទូរទស្សន៍ មានភារកិច្ច ៖**

-ធានាការផ្សាយរបស់ទូរទស្សន៍

-គ្រប់គ្រងវិសាលភាព គុណភាព នៃការផ្សាយរបស់ទូរទស្សន៍

-សិក្សាស្រាវជ្រាវបច្ចេកទេស លើកកំពស់អភិវឌ្ឍន៍ មូលដ្ឋានបច្ចេកទេសរបស់ទូរទស្សន៍ជាតិកម្ពុជា ។

នាយកដ្ឋានបច្ចេកទេសទូរទស្សន៍ ដឹកនាំដោយនាយក១រូប មានឋានៈស្មើប្រធាននាយកដ្ឋាន អមដោយនាយករង មានឋានៈស្មើអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

## ជំពូកទី ១០

## អំពីអង្គភាពមូលដ្ឋាន

**មាត្រា ៣៤ .-**

នៅតាមខេត្ត-ក្រុងនីមួយៗ មានមន្ទីរពត៌មានខេត្ត-ក្រុង ខ័ណ្ឌ ដែលទទួលបន្ទុកអនុវត្ត និងសំរបសំរួលសកម្មភាពរបស់ក្រសួង ។

## ជំពូកទី ១១

## អំពីអង្គភាពត្រួតពិនិត្យ ហិរញ្ញវត្ថុ

**មាត្រា ៣៥ .-**

អង្គភាពត្រួតពិនិត្យ ហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើងដោយ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ តាមល័ក្ខខ័ណ្ឌ នៃបទបញ្ញត្តិណាត់ ក្នុងអនុក្រឹត្យលេខ ៨១ ចុះថ្ងៃទី១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតស្ថាប័នត្រួតពិនិត្យ ហិរញ្ញវត្ថុ លើការចំណាយថវិកាតាមក្រសួងនីមួយៗ ។

## ជំពូកទី ១២

## អវសានប្បញ្ញត្តិ

**មាត្រា ៣៦ .-**

ការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងនៅរដ្ឋបាលកណ្តាល និងអង្គភាពមូលដ្ឋាន ចាប់ពីថ្នាក់ក្រោមនាយកដ្ឋាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងពត៌មាន ។

មាត្រា ៣៧ .-

ភារកិច្ចទាំងឡាយដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ស្ថាប័នដទៃ រដ្ឋមន្ត្រីក្រសួងព័ត៌មាន ត្រូវសហការគ្នាជាមួយ ប្រធានស្ថាប័ន នៃស្ថាប័នដទៃនោះ ដើម្បីបែងចែកការងារទទួលខុសត្រូវ និងអនុវត្តការងារទាំងនោះ តាមរយៈប្រកាសរួម របស់រដ្ឋមន្ត្រីក្រសួងព័ត៌មាន និងប្រធានស្ថាប័នទាំងនោះ ។

មាត្រា ៣៨ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣៩ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងព័ត៌មាន និងរដ្ឋមន្ត្រី រដ្ឋលេខាធិការទាំងអស់ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ សីហា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

ភ្នំពេញ,ថ្ងៃទី ខែ កក្កដា ឆ្នាំ ១៩៩៩

ទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងព័ត៌មាន

ហត្ថលេខានិងត្រា

លី ធាយស្រេង

***



ឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យលេខ ៧០ អនក្រ-បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩
អង្គការលេខ នៃក្រសួងពត៌មានថ្មី
រដ្ឋមន្ត្រី
រដ្ឋលេខាធិការ
អនុរដ្ឋលេខាធិការ
ខុទ្ទកាល័យ-ទីប្រឹក្សា
អគ្គរដ្ឋបាល-សោតទស្សន៍
ន.រដ្ឋបាលទូទៅ
នាយកដ្ឋានបុគ្គលិ
ន.ផែនការ.គណន.ហិរញ្ញ
ន.សំភារៈ បរិក្ខារ
ន.មណ្ឌលពត៌មាន
ន.សោតទស្សន៍
ន.សហប្រ.អន្តរជាតិ
អគ្គ.ទីភ្នាក់ងារសារពត៌.កម្ពុជា"AKP"
ន.ពម.ក្នុង+ក្រៅប្រទេស
ន.ពម.ផ្សាយទៅបរទេស
ន.កាសែតកម្ពុជា
នទស្សនាវដ្តី
នាយកដ្ឋានរូបថត
ន.ឯកសារ-បណ្ណាល័យ
ន.បច្ចេកទេស-បោះពុម្ពផ្សាយ
អគ្គ.វិទ្យុជាតិកម្ពុជា" RNK"
ន.ពម.ក្នុង+ក្រៅប្រទេស
ន.ពម.ផ្សាយបរទេស
ន.ផលិតកម្មវិធី
ន.បច្ចេកទេស
អគ.ទូ.ទស្សន៍ជាតិកម្ពុជា " TVK"
ន.ពម.ក្នុង+ក្រៅប្រទេស
ន.។ម.ផ្សាយទៅបរទេស
ន.ផលិតកម្មវិធី
ន.បច្ចេកទេស
បណ្ឌ.បប.វិក្រិត្ត.ជីវៈសារ.ពម
អធិការដ្ឋាន
មន្ទីរព.មាគខេត្ត-ក្រុង
អង្គភាពត្រួតពិនិត្យ ហិ.វត្ថុ

ឧបសម្ព័ន្ធទី២ នៃ អនុក្រឹត្យលេខ ៧០ អនក្រ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩

## ខ្លឹមសារ រូបសញ្ញារបស់ក្រសួងព័ត៌មាន

១ រង្វង់មូលតំណាងអោយពិភពលោក ។

២ ពណ៌ក្រហម ពណ៌ខៀវ និង ពណ៌ស ជាពណ៌របស់ទង់ជាតិកម្ពុជា ។

៣ ខ្សែពណ៌ស នៅចំកណ្តាល ដែលមានរាងជាប្រេកង់ (រលកធាតុអាកាស)ផង និងមានរាងប្រាសាទអង្គរវត្តផង តំណាងអោយជាតិ សាសនា ព្រះមហាក្សត្រ ។

៤ ខ្សែពណ៌ខៀវ ក្រហម ដែលមានរាងកោងព័ទ្ធជុំវិញរង្វង់មូលរាងផែនដី ជានិមិត្តសញ្ញា នៃការផ្សព្វផ្សាយទូលំទូលាយក្នុងលំហអាកាស ។

៥ អក្សរក្រសួងព័ត៌មាន ពណ៌ស តំណាងអោយភាពស្អាតស្អំ បរិសុទ្ធមិនលំអៀង ។

ឧបសម្ព័ន្ធទី៣ នៃ អនុក្រឹត្យលេខ ៧០ អនក្រ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩

ខ្លឹមសារ រូបសញ្ញារបស់អគ្គនាយកដ្ឋាន AKP

# ទីភ្នាក់ងារសារព័ត៌មានកម្ពុជា

# AGENCE KAMPUCHEA PRESSE

១ ប្រាសាទអង្គរវត្ត ជាតំណាងអោយ វប្បធម៌ និង អរិយធម៌ របស់ជាតិខ្មែរ ។

២ រូបសីង្ហ តំណាងអោយ ឫទ្ធិអំណាច ក្នុងការឃោសនាផ្សព្វផ្សាយរបស់រាជរដ្ឋាភិបាល ។

៣ រង្វង់មូលជាតំណាងអោយ អធិបតេយ្យភាពរបស់ជាតិទាំងមូល ។

៤ ពណ៌ខៀវ ក្រហម ស ជាពណ៌របស់ទង់ជាតិកម្ពុជា ។

## ឧបសម្ព័ន្ធទី៤ នៃ អនុក្រឹត្យលេខ ៧០ អនក្រ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩

## ខ្លឹមសារ រូបសញ្ញារបស់វិទ្យុជាតិកម្ពុជា

១ រូបសញ្ញារបស់វិទ្យុជាតិកម្ពុជា មានរាងជារង្វង់ ដែលស្ថិតនៅលើផ្ទៃពណ៌ស ។ រូបសញ្ញានេះ ផ្តើមចេញពីរូបប្រាសាទអង្គរវត្តពណ៌ "ស" នៅកណ្តាលរង្វង់ពណ៌ក្រហម ដោយបញ្ចេញរស្មីពណ៌ខៀវ ទៅខាងមុខ ចំនួន៧ជាន់ ។ នៅខាងមុខរូបប្រាសាទ មានចារឹកអក្សរពណ៌ ក្រហម ដែលមានន័យថា វិទ្យុជាតិកម្ពុជា ចំពាក់កណ្តាលរង្វង់ ។ រីឯនៅខាងក្រោមអក្សរនេះ មានរូបរាងពងក្រពើ ដែលសរសេរអក្សរកាត់ថា RNK ដែលភាសាបារាំងមានន័យថា RADIO NATIONALE DU KAMPUCHEA រំលេចដោយពណ៌ទឹកសមុទ្រ ។

២ រូបប្រាសាទពណ៌ស ស្ថិតលើផ្ទៃពណ៌ក្រហម ដែលព័ទ្ធជុំវិញដោយរង្វង់ពណ៌ខៀវ ជាតំណាងទង់ជាតិ នៃព្រះរាជាណាចក្រកម្ពុជា ។

រស្មីពណ៌ខៀវទាំងប្រាំពីរ ជាតំណាងលក្ខណៈបច្ចេកទេស នៃរលកសញ្ញាការផ្សាយរបស់វិទ្យុ ។

ចំណែកអក្សរ RNK ស្ថិតនៅក្នុងរង្វង់ពងក្រពើ គឺតំណាងអោយការផ្សាយជាភាសាបរទេសទៅលើពិភពលោក ។

ឧបសម្ព័ន្ធទី ៥ នៃអនុក្រឹត្យលេខ ៧០ អនក្រ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩

## ខ្លឹមសារ រូបសញ្ញារបស់ ទូរទស្សន៍ជាតិកម្ពុជា

ក្នុងគោលបំណងអោយស្ថានីយ៍ទូរទស្សន៍ជាតិកម្ពុជា មានអត្តសញ្ញាណរបស់ខ្លួនពិតប្រាកដ និងងាយស្រួលដល់ទូរទស្សនិកជនបានស្គាល់ ឧបករណ៍នៃការផ្សាយរបស់រាជរដ្ឋាភិបាល អគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា បានបង្កើតជារូបសញ្ញាមួយ ដែលមានចំណុចសំខាន់ៗដូចខាងក្រោម :

រូបសញ្ញារបស់ទូរទស្សន៍ជាតិកម្ពុជា គឺមានរាងបួនជ្រុងទ្រវែង ដោយមានទទឹង២ភាគ បណ្ដោយ ៣ភាគ ។ មានពណ៌ក្រហម រាងចតុកោណព្នាយ ពុះកាត់ផ្ទៃពណ៌ខៀវ រាងចតុកោណកែង នៃផ្ទៃក្របខ្ញុំទាំងមូល ។

ក្នុងចំហៃផ្ទៃក្រឡា ដែលមានពណ៌ខៀវ ក្រហម មានអក្សរឆ្លាក់មូល ទទក មានពណ៌ "ស" រឹមពណ៌ខ្មៅ ដែលស្ថិតនៅក្នុងចំហៃផ្ទៃក្រឡា១ភាគ នៃទទឹង និង ៣ភាគនៃបណ្ដោយ ហើយអក្សរឡាតាំង TVK មានពណ៌ "ស" រឹមពណ៌ខ្មៅ ដែលស្ថិតនៅក្នុងរង្វង់រាងពងក្រពើ មានផ្ទៃពណ៌ "ស" គែមពណ៌ខ្មៅ ជានិមិត្តរូបពិភពលោក ស្ថិតនៅ១ភាគ នៃទទឹង និង១ភាគ៣ នៃ បណ្ដោយ ផ្នែកខាងក្រោម ។

អក្សរ ទទក ពណ៌ "ស" រឹមខ្មៅ អក្សរកាត់ ឡាតាំង TVK ពណ៌ "ស" រឹមខ្មៅ ជាអក្សរកាត់នៃឈ្មោះរបស់ស្ថានីយ៍ សំរាប់បង្ហាញអត្តសញ្ញាណរបស់ខ្លួន អោយទូរទស្សនិកជនស្គាល់ "ទូរទស្សន៍ជាតិកម្ពុជា" ទាំងនៅក្នុងផ្ទៃប្រទេស និងលើឆាកអន្តរជាតិ ។

ពណ៌ខៀវ ក្រហម ស ជាពណ៌របស់ទង់ជាតិកម្ពុជា ។

# អនុក្រឹត្យ លេខ ៥៥០ អនក្រ.តត

## ស្តីពី

## ការតែងតាំងឋានន្តរស័ក្តិនាយនគរបាលជាតិ

* * *

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម លេខ ០២ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/០៣៩៨/០៨៣ ចុះថ្ងៃទី ៦ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ សញ្ញា និងរូបភាព ឋានន្តរស័ក្តិ នគរបាលជាតិ

-បានឃើញអនុក្រឹត្យ លេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ

-តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

មាត្រា ១ .- ត្រូវបានតែងតាំង ឋានន្តរស័ក្តិ ថ្នាក់វរសេនីយ៍ឯក ជូននាយនគរបាលជាតិ ដូចខាងក្រោម ៖

-លោក ជុត ឈេន អនុប្រធាននាយកដ្ឋាននគរបាលជាតិរដ្ឋបាល

-លោក លីវ ម៉ុទ អនុប្រធាននាយកដ្ឋាននគរបាលជាតិរដ្ឋបាល

-លោក នូ សារិ អនុប្រធាននាយកដ្ឋាននគរបាលសេដ្ឋកិច្ច

-លោក ខ្ទិត ថន អនុប្រធានអង្គភាពអន្តរាគមន៍

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ·រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ និងអស់លោកដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា.និងត្រា

ហ៊ុន សែន

# អនុក្រឹត្យ លេខ ៤៥១ អនក្រ.តត

# ស្តីពី

# ការតែងតាំងមន្ត្រីរាជការ

* * *

# រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមសំណើរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សំរេច

**មាត្រា ១ .-** តែងតាំង លោក **ឃីវ សុខុម** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស នៃក្រសួងពាណិជ្ជកម្ម ជាទីប្រឹក្សាអមស្ថានទូត នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំព្រះរាជាណាចក្រថៃ ទទួលបន្ទុកសហប្រតិបត្តិការសេដ្ឋកិច្ចពាណិជ្ជកម្ម និងទេសចរណ៍ ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

# អនុក្រឹត្យ លេខ ៤៥២ អនក្រ.តត

# ស្តីពី

# ការតែងតាំងមន្ត្រីរាជការ

* * *

# រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមសំណើរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

**សំរេច**

មាត្រា ១ .- តែងតាំង លោក អ៊ុង គឹមយ៉ុន បច្ចុប្បន្នអនុប្រធាននាយកដ្ឋានជំរុញការនាំចេញ នៃក្រសួងពាណិជ្ជកម្ម ជាទីប្រឹក្សាអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសហព័ន្ធម៉ាឡេស៊ី ទទួលបន្ទុកសហប្រតិបត្តិការ ផ្នែកសេដ្ឋកិច្ចពាណិជ្ជកម្ម និងទេសចរណ៍ ។

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យ លេខ ៤៥៣ អនក្រ.តត

## ស្ដីពី

## ការផ្លាស់ប្ដូរមន្ត្រីរបស់

## មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា (CMAC)

* * *

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩[illegible] ស្ដីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែល[illegible]កាស អោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦៩៩/១៣៨ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ១៩[illegible] [illegible]ការ បង្កើតមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា

-យោងតាមសំណើរបស់មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា

**សំរេច**

**មាត្រា ១** .- ត្រូវបានផ្លាស់ប្តូរភារកិច្ច លោក **នៀម ជូនៀង** អគ្គនាយករង នៃមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា អោយទៅបំរើការងារជាបណ្តោះអាសន្ន ក្នុងក្រុមប្រឹក្សាភិបាល នៃមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា ។

**មាត្រា ២** .- បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣** .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្រធានមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យ លេខ ៥៥៥ អនក្រ.តត

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

* * *

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម លេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ

-បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ

**សំរេច**

**មាត្រា ១ .-** តែងតាំង លោក **ជ័យ សាទឿ** ជាអគ្គនាយករងក្រុមហ៊ុនគាំពារៈ កសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី កសិកម្មរុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យ លេខ ៤៥៥ អនក្រ.តត

**ស្តីពី**

**ការតម្លើងឋានន្តរស័ក្តិ តែងតាំង និងផ្លាស់ប្តូរមុខងារ**

* * *

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាល

-បានឃើញព្រះរាជក្រម លេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមសំណើរបស់សម្តេចរដ្ឋមន្ត្រីក្រសួងការពារជាតិ

**សំរេច**

**មាត្រា ១ .-** ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ វរសេនីយ៍ឯក តែងតាំង និង ផ្លាស់ប្តូរមុខងារនាយទាហាន ក្នុងកងយោធពលខេមរភូមិន្ទ ជូនចំពោះ លោកវរសេនីយ៍ទោ **ឆេង សំអាន** អត្តលេខ ០០០៦៧៩ នាយផ្នែកឃ្លាំងទូទៅ ការិយាល័យទី ៤ បច្ចុប្បន្នជានាយករង នាយកដ្ឋានផ្គត់ផ្គង់ អគ្គនាយកដ្ឋានភស្តុភា - ហិរញ្ញវត្ថុ ក្រសួងការពារជាតិ ។

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យ លេខ ៤៥៦ អនក្រ.តត

## ស្តីពី

## ការដាក់អោយចូលនិវត្តន៍ របស់មន្ត្រីរាជការ

* * *

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញអនុក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម លេខ ០៦ នស/៩៤ ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

## សំរេច

មាត្រា ១ .- ត្រូវបានដាក់អោយចូលនិវត្តន៍ នូវមន្ត្រីរាជការ ដូចមានរាយនាមខាងក្រោម ៖

| | |
|---|---|
| ១-លោក ខិត ស៊ុនថន | បច្ចុប្បន្នប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងធម្មការ និងសាសនា |
| ២-លោក យី ធន់ | បច្ចុប្បន្ន ជាទីប្រឹក្សាអមក្រសួងធម្មការ និងសាសនា |
| ៣-លោក យ៉េន ឌុន | បច្ចុប្បន្ន ប្រធាននាយកដ្ឋានធម្មការ នៃក្រសួងធម្មការនិងសាសនា |
| ៤-លោក ខិម ខែម | បច្ចុប្បន្ន ប្រធាននាយកដ្ឋានពុទ្ធសាសនបណ្ឌិត នៃក្រសួងធម្មការ និងសាសនា |

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួង ធម្មការនិងសាសនា រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់

ក្រសួងពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ឱ្យបានសំរេច ចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

# III- ការងារបណ្តាក្រសួង

## ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សារាចរ

រាជធានីភ្នំពេញ,ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ១៩៩៩

### សារាចរ លេខ ០១២ សរ.សហវ

### ស្តីពីការប្រមូលចំណូលពីទ្រព្យសម្បត្តិសាធារណៈ

* * *

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានតួនាទីភារកិច្ចគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋទាំងមូល បានកំណត់ទិសដៅសំរាប់ការគ្រប់គ្រងក្នុងក្របខ័ណ្ឌនៃសមត្ថកិច្ចរបស់ខ្លួន តាមប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ នៃរបបសេដ្ឋកិច្ចទីផ្សារ។

ដើម្បីធានាដល់ការគ្រប់គ្រងថវិកា ខាងផ្នែកចំណូលពីការជួលទ្រព្យសម្បត្តិសាធារណៈ ដូចជា ភាស៊ីផ្សារ កំពង់ផែ ចំណតរថយន្ត ចំណតទូកកាណូត-សៀវត្រី (កំពង់ផែនេសាទ) ទីសត្តឃាតដ្ឋាន ......។ល។ និងទ្រព្យសម្បត្តិផ្សេងៗទៀត ដែលមានក្នុងវិស័យសាធារណៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំដល់ខេត្ត-ក្រុង និងស្ថាប័ន នានាដូចតទៅ ៖

១-ការដាក់ជួលទ្រព្យសម្បត្តិសាធារណៈដូចជា ផ្សារ កំពង់ផែ ចំណតរថយន្ត ចំណតទូក កាណូត សៀវត្រី (កំពង់ផែនេសាទ) ទីសត្តឃាតដ្ឋាន .....។ល។ និងទ្រព្យសម្បត្តិផ្សេងៗទៀត មានក្នុងវិស័យ សាធារណៈ ត្រូវធ្វើការប្រមូលផ្តុំដេញថ្លៃទាំងអស់ នៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត-ក្រុង ដោយរៀបចំលិខិតបទដ្ឋាន តាមនីតិវិធីដេញថ្លៃជាសាធារណៈស្របតាមអាណត្តិនីមួយៗ ក្រោមការរៀបចំដឹកនាំរបស់អភិបាលខេត្ត-ក្រុង។

-កំណត់ហេតុនៃការដេញថ្លៃ និងសៀវភៅបន្ទុកភាស៊ី ត្រូវមានការឯកភាពយល់ព្រមពីរដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

លោកប្រធានមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្ត-ក្រុង ត្រូវចាត់មន្ត្រីមានសមត្ថកិច្ចធ្វើការស្រាវជ្រាវ បន្ថែម នូវទ្រព្យសម្បត្តិសាធារណៈទាំងឡាយណា ដែលអាចដាក់ជួល និងត្រូវរៀបចំបែបបទ លិខិតបទដ្ឋាននានា សំរាប់ធ្វើការដេញថ្លៃនូវទ្រព្យសម្បត្តិសាធារណៈទាំងនោះ ។

ចំណូលបានពីការជួលផ្ទៃ នូវទ្រព្យសម្បត្តិសាធារណៈទាំងនោះ (យោងតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត-ក្រុង ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ) ត្រូវបង់ចូលខ្ទង់ថវិកាខេត្ត-ក្រុងទាំងអស់ នៅរតនាគារខេត្ត-ក្រុង ។

២-ប្រាក់កក់ធានាអាសន្ន ប្រាក់កក់ធានាស្ថាពរ ប្រាក់ថ្លៃឈ្នួល និង ប្រាក់ពិន័យយឺតយ៉ាវ ត្រូវបង់នៅរតនាគារខេត្ត-ក្រុង សាមីជាប្រាក់រៀល ដោយបំពេញបែបបទនៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត-ក្រុង។

-ត្រូវជំរុញផ្ទេរប្រាក់ទាំងនេះចូលថវិកាខេត្ត-ក្រុងជាបន្ទាន់ មិនអនុញ្ញាតអោយទុកក្នុងគណនីប្រាក់បញ្ញើ របស់រតនាគារ ឬស្ថាប័នណាមួយឡើយ ។

ត្រូវគោរព និងអនុវត្តដោយម៉ឺងម៉ាត់បំផុត តាមបទបញ្ញត្តិគតិយុត្តនានា ។ ករណីដែលស្ថាប័នជំនាញ គ្រប់គ្រងលើចំណូលពីការជួលទ្រព្យសម្បត្តិសាធារណៈ បណ្តែតបណ្តោយពុំមានវិធានការម៉ឺងម៉ាត់អោយទាន់ពេលវេលា បណ្តោយអោយបាត់បង់ចំណូលនោះ ប្រធានស្ថាប័នជាអ្នកទទួលខុសត្រូវទាំងស្រុង ។

៣-ក្នុងករណីជួសជុលកែលំអ សាងសង់ដូចជា ផ្សារ ចំណតរថយន្ត ចំណតទូក-កាណូត-កំពង់ផែ-ឃ្លាំង (កំពង់ផែទេសចរ) ទីសត្តឃាតដ្ឋាន .....។ល។ រួមទាំងការប្រមូលនិងដឹកជញ្ជូនសំរាម ដើម្បីធ្វើអាជីវកម្ម-សេវាកម្ម ក៏ដូចជាការវិនិយោគទុនរកផលលើទ្រព្យសម្បត្តិសាធារណៈផ្សេងៗទៀត ត្រូវធ្វើសំណើសុំការយល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

៤-រាល់ចំណូលអាករគ្រប់ប្រភេទ ពីទ្រព្យសម្បត្តិសាធារណៈទាំងឡាយ ទោះមាន ឬគ្មានការវិនិយោគថ្មីក្តី ត្រូវរៀបចំដាក់អោយដេញថ្លៃជាសាធារណៈ ។ ប្រសិនបើមិនអាចដាក់អោយដេញថ្លៃបានទេ ត្រូវស្នើសុំការយល់ព្រមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

-ពេលបញ្ចប់កិច្ចសន្យា ទីតាំង និងទ្រព្យសម្បត្តិសាធារណៈ ដូចជាអាគារ ផ្ទះល្វែង ... និង តូប-រានដែលបានជួលអោយអាជីវករលក់ដូរក្នុង និងក្បែរបរិវេណផ្សារ ត្រូវប្រគល់ជាទ្រព្យសម្បត្តិរដ្ឋវិញទាំងអស់ ។ រីឯថ្លៃឈ្នួលអាគារ ផ្ទះល្វែង ...និងតូប-រាន ត្រូវកំណត់ថ្លៃសារជាថ្មីសំរាប់ជួលក្នុងអាណត្តិថ្មី ហើយចំណូលពីការជួលត្រូវបង់ចូលថវិកាខេត្ត-ក្រុង (យោងច្បាប់ ស្តីពីរបបហិរញ្ញវត្ថុ និង ទ្រព្យសម្បត្តិរបស់ខេត្ត-ក្រុង) ។

៥-មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្ត-ក្រុង និងក្រុមហិរញ្ញវត្ថុរបស់សាលាខេត្ត-ក្រុង ជាអ្នកតាមដាន និងគ្រប់គ្រងចំណូលនេះ ។ មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្ត-ក្រុង ត្រូវរាយការណ៍ស្ថានភាពការងារនេះអោយបានទៀងទាត់ជារៀងរាល់ខែ នៅថ្ងៃទី ០៥ នៃខែបន្ទាប់ ទៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ) ។

រាល់ការដេញថ្លៃទ្រព្យសម្បត្តិសាធារណៈ ត្រូវមានតំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុចូលរួម ។ ក្រោយពីបានទទួលសារាចរនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្ព័ន្ធជា ក្រសួងស្ថាប័នពាក់ព័ន្ធ គ្រប់សាលាខេត្ត-ក្រុង នឹងមានវិធានការអនុវត្តក្នុងការប្រមូលចំណូលពីទ្រព្យសម្បត្តិសាធារណៈ អោយប្រសិទ្ធភាពខ្ពស់បំផុតជាក់ជាពុំខាន ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា និងត្រា

គាត ឈន់

## ២- ធនាគារជាតិនៃកម្ពុជា

### ប្រកាស

### ប្រកាស លេខ ធ ៩៩៨/៣៩៣/ប្រក

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩

### ស្ដីពីការគ្រប់គ្រងការប្ដូរប្រាក់

### ចំពោះអាជីវករប្ដូរប្រាក់

* * *

### អគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃធនាគារជាតិនៃកម្ពុជា ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ ១៩៩៦

-បានឃើញច្បាប់ ស្ដីពីការគ្រប់គ្រងការប្ដូរប្រាក់ ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រមលេខ ជស/រកម/០៨៩៧/០៣ ចុះថ្ងៃទី២២ ខែ សីហា ឆ្នាំ ១៩៩៧

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣៩៨/៩៥ ចុះថ្ងៃទី១០ ខែ មិថុនា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជា

-បានឃើញការចាំបាច់ នៃវិធានការគ្រប់គ្រងការប្ដូរប្រាក់

-តាមសំណើរបស់នាយកដ្ឋានគ្រប់គ្រងការប្ដូរប្រាក់ និងអគ្គលេខាធិការ

### សំរេច

**ប្រការ ១ :** បុគ្គល ឬក្រុមបុគ្គល អាចធ្វើអាជីវកម្មប្ដូរប្រាក់បាន ទោះស្ថិតក្នុងទីតាំងអចល័ត ឬ ទីតាំងចល័តក្ដី អោយតែទទួលបានការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជា ។ បុគ្គលទាំងឡាយណាដែលស្នើសុំទៅធនាគារជាតិនៃកម្ពុជា ដើម្បីធ្វើអាជីវកម្មប្ដូរប្រាក់ ត្រូវមានអាយុចាប់ពី ១៨ឆ្នាំឡើងទៅ មានទីលំនៅអចិន្ត្រៃយ៍ ដែលមានវិញ្ញាបនបត្រត្រឹមត្រូវដោយអាជ្ញាធរក្នុងមូលដ្ឋានដែលខ្លួនរស់នៅ និងត្រូវបានអាជ្ញាធរផ្ដល់ការអនុញ្ញាតអំពីទីតាំងអាជីវកម្ម ។

**ប្រការ ២ :** បុគ្គលដែលស្នើសុំធ្វើអាជីវកម្មប្ដូរប្រាក់ ត្រូវបង្ហាញភស្ដុតាងថាខ្លួនមានគណនីប្រាក់បញ្ញើជារៀល និង / ឬ គណនីរូបិយប័ណ្ណ សំរាប់ប្រើសកម្មភាពអាជីវកម្ម នៅធនាគារពាណិជ្ជកម្មណាមួយ តាមការជ្រើសរើសរបស់ខ្លួន ។ គណនីប្រាក់រៀលត្រូវតែរក្សាអោយបាននូវសមតុល្យប្រចាំថាមធ្យម ស្មើប្រាំលាន (៥.០០០.០០០) រៀល ក្នុងខែនីមួយៗ ។ ធនាគារពាណិជ្ជកម្មដែលរក្សាគណនីខាងលើ ត្រូវផ្ញើសំរង់គណនី នៅរាល់ដើមខែ ជូនធនាគារជាតិនៃកម្ពុជា ។

**ប្រការ ៣ :** បុគ្គល ឬក្រុមបុគ្គល ដែលត្រូវបានទទួលការអនុញ្ញាត អោយប្រកបអាជីវកម្មប្ដូរប្រាក់តទៅនេះហៅថា "បុគ្គលប្រតិបត្តករ" ត្រូវគោរពបទបញ្ញត្តិទាំងឡាយរបស់ធនាគារជាតិនៃកម្ពុជា និងច្បាប់របស់រដ្ឋ ។

**ប្រការ ៤ :** បុគ្គលប្រតិស្រុតត្រូវធ្វើប្រតិបត្តិការប្តូរប្រាក់ក្នុងទីតាំងដែលអាជ្ញាធរមានសមត្ថកិច្ច បានកំណត់ដោយដាក់បង្ហាញនូវផ្លាកជាអក្សរថា " ប្តូរប្រាក់ " និងអក្សរឡាតាំង "MONEY CHANGER" ព្រមទាំងអាសយដ្ឋាន "លេខផ្ទះ លេខផ្លូវ " លិខិតអនុញ្ញាតរបស់ធនាគារជាតិនៃកម្ពុជា និងតារាងអត្រាប្តូរប្រាក់ប្រចាំថ្ងៃរបស់ខ្លួន ។

**ប្រការ ៥ :** បុគ្គលប្រតិស្រុត អាចធ្វើបានតែប្រភេទប្រតិបត្តិការទាក់ទងនឹងមធ្យោបាយ ទូទាត់ជារូបិយប័ណ្ណ ដូចខាងក្រោម :

១-ទិញក្រដាសប្រាក់ជារូបិយប័ណ្ណ ឬ មូលប្បទានប័ត្រទេសចរណ៍ ដែលអាចទូទាត់ជារូបិយប័ណ្ណ កំពុងមានចំណែកចរាចរជាអន្តរជាតិ ។

២-លក់ក្រដាសប្រាក់ជារូបិយប័ណ្ណ ឬ មូលប្បទានប័ត្រទេសចរណ៍ ជារូបិយប័ណ្ណ ដោយធនាគារជាតិនៃកម្ពុជា ឬ ធនាគារពាណិជ្ជ

-ឬ ដាក់ផ្ញើក្នុងគណនីរបស់ខ្លួន នៅធនាគារពាណិជ្ជ

-លក់រូបិយប័ណ្ណ ជាការផ្ទេរគណនីអោយអ្នកដឹកនាំទំនិញចូល

-លក់រូបិយប័ណ្ណ អោយបុគ្គលដែលមានលិខិតអនុញ្ញាតអោយទៅបរទេស តាមចំនួនប្រាក់ខ្ពស់បំផុតមិនលើសពី ប្រាំពាន់ (៥.០០០) ដុល្លារអាមេរិក ក្នុងម្នាក់ៗ ក្រោយពីបានបង្ហាញឯកសារពាក់ព័ន្ធដល់ការធ្វើដំណើរទៅបរទេស

-លក់រូបិយប័ណ្ណ អោយភ្ញៀវបរទេស ដែលមានវិញ្ញាបនប័ត្រ បញ្ជាក់ការប្តូរប្រាក់ពេលចូលមកកម្ពុជា ប៉ុន្តែចំណាយមិនទាន់អស់ នៅពេលត្រឡប់ទៅវិញ

-លក់រូបិយប័ណ្ណ ដល់បុគ្គលដទៃទៀត ក្នុងចំនួនប្រាក់មិនលើសពី ពីររយ (២០០) ដុល្លារអាមេរិក ។

**ប្រការ ៦ :** ក្នុងការទិញ លក់រូបិយប័ណ្ណ បុគ្គលប្រតិស្រុត ត្រូវចេញវិញ្ញាបនប័ត្រប្តូរប្រាក់ តាមគំរូណែនាំដោយ ធនាគារជាតិនៃកម្ពុជា ក្នុងនោះត្រូវមានលំដាប់លេខ ស៊េរី (Serie) កាលបរិច្ឆេទ ទិញ-លក់ឈ្មោះ និងអាសយដ្ឋាននៃអ្នកទិញ/អ្នកលក់ ចំនួនទឹកប្រាក់ជារូបិយប័ណ្ណ , ប្រភេទរូបិយប័ណ្ណ អត្រាប្តូរប្រាក់ ចំនួនទឹកប្រាក់ជារៀល និងមានហត្ថលេខា បុគ្គលប្រតិស្រុត ឬ អ្នកតំណាង ។

**ប្រការ ៧ :** រាល់លើកនៃការទិញ-លក់ បុគ្គលប្រតិស្រុត ត្រូវចេញវិញ្ញាបនប័ត្រជាពីរច្បាប់ ក្នុងនោះច្បាប់ដើមត្រូវប្រគល់អោយអតិថិជន រីឯច្បាប់ចំលងត្រូវរក្សាទុកសំរាប់កត់ត្រាក្នុងសៀវភៅបញ្ជីប្រចាំថ្ងៃរបស់ខ្លួន ។

**ប្រការ ៨ :** បុគ្គលប្រតិស្រុត មិនអនុញ្ញាតអោយធ្វើសកម្មភាពទទួលប្រាក់ បញ្ញើ ឬ អោយខ្ចីឥណទាន ឬ សកម្មភាពដទៃទៀតដែលពាក់ព័ន្ធដល់សកម្មភាពអាជីវកម្មធនាគារពាណិជ្ជផ្សេងៗ ។

**ប្រការ ៩ :** បុគ្គលប្រតិស្រុត ត្រូវរក្សាអោយបានត្រឹមត្រូវ នូវសៀវភៅបញ្ជី នៃគ្រប់ប្រតិបត្តិការ ទិញ-លក់រូបិយប័ណ្ណ និងមូលប្បទានប័ត្រទេសចរណ៍ អាចទូទាត់ បានជារូបិយប័ណ្ណ ។ សៀវភៅបញ្ជី ព្រមទាំងឯកសារទិញ-លក់ ដូចមានចែងខាងលើ ត្រូវតែរក្សាទុកនៅទីតាំងប្តូរប្រាក់របស់ខ្លួន និងត្រូវរៀបរយជាស្រេច ដើម្បីបង្ហាញជូនអ្នកតំណាងធនាគារជាតិនៃកម្ពុជានៅរាល់អធិការកិច្ចតាមកំណត់ ឬតាមការចាំបាច់ (ដោយមិនមានការជូនដំណឹងជាមុន) ។

ប្រការ ១០ : បុគ្គលប្រតិស្រុត ត្រូវធ្វើរបាយការណ៍អំពីប្រតិបត្តិការ និងស្ថានភាពរូបិយប័ណ្ណប្រចាំសប្តាហ៍និមួយៗ ជូនធនាគារជាតិនៃកម្ពុជា (នាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់) នៅមុនពេលថ្ងៃអង្គារ៍ នៃសប្តាហ៍បន្ទាប់ ។ ប្រតិបត្តិការប្តូរប្រាក់ប្រចាំថ្ងៃត្រូវចុះបញ្ជីក្នុងរបាយការណ៍ ។ ចំពោះថ្ងៃដែលពុំមានសកម្មភាពប្តូរប្រាក់ ត្រូវកត់ត្រាថា "គ្មាន" ។ ក្នុងរបាយការណ៍ត្រូវតែបញ្ជាក់អំពីសមតុល្យ "សំណល់"រូបិយប័ណ្ណនៅចុងថ្ងៃ នៃសប្តាហ៍និមួយៗ ។

ប្រការ ១១ : លិខិតអនុញ្ញាតធ្វើអាជីវកម្មប្តូរប្រាក់ ដែលចេញផ្តល់ដោយធនាគារជាតិនៃកម្ពុជា មានសុពលភាពរយៈពេល១២ខែ ។ បុគ្គលប្រតិស្រុត ដែលចង់បន្តអាជីវកម្មរបស់ខ្លួន ត្រូវដាក់ពាក្យសុំជាថ្មី ក្នុងរយៈពេល១៥ថ្ងៃ មុនថ្ងៃផុតកំណត់ សុពលភាព។

ប្រការ ១២ : លិខិតអនុញ្ញាតអាចត្រូវដកហូតវិញបាន ក្នុងករណីដែលបុគ្គលប្រតិស្រុត បានប្រព្រឹត្តល្មើសនូវបទបញ្ញត្តិនិងលក្ខខណ្ឌផ្សេងៗដូចខាងក្រោម :

- មិនបង់ប្រាក់ពន្ធអាករផ្សេងៗ ក្រោយពេលធនាគារជាតិបានទទួលដំណឹងជាផ្លូវការ និង ជាលាយលក្ខណ៍អក្សរពីក្រសួងមានសមត្ថកិច្ច
- មិនធ្វើរបាយការណ៍ប្រចាំសប្តាហ៍ជូនធនាគារជាតិរយៈពេល ១ខែ
- មិនតាំងបង្ហាញលិខិតអនុញ្ញាត និងអត្រាប្តូរប្រាក់ប្រចាំថ្ងៃរបស់ខ្លួន ។
- មិនបានបំពេញ ឬ រក្សាឯកសារប៉ូតូប្តូរប្រាក់ សៀវភៅកត់ត្រាប្រតិបត្តិការ និងមិនបង្ហាញឯកសារទាំងនោះ ជូនមន្ត្រីទទួលបន្ទុកធ្វើអធិការកិច្ចរបស់ភ្នាក់ងារ ធនាគារជាតិនៃកម្ពុជា
- មិនបង្ហាញឲ្យឃើញនូវកិច្ចការជំនួញរបស់ខ្លួន ក្នុងបំណងលាក់បាំង ដើម្បីទទួលបានប្រាក់ចំណេញហួសហេតុ ឬ រក្សាទុករូបិយប័ណ្ណក្នុងគោលដៅធ្វើវិចារកម្ម ឬ គំរាមកំហែងបំណងទុច្ចរិតផ្សេងៗទៀត
- ប្រព្រឹត្តនូវសកម្មភាពផ្សេងៗ ដែលផ្ទុយនឹងច្បាប់របស់រដ្ឋ ។

ប្រការ ១៣ : ករណីផ្អាក ឬ បញ្ឈប់សកម្មភាព ឬ ប្តូរទីតាំងធ្វើអាជីវកម្ម បុគ្គលប្រតិស្រុត ត្រូវដាក់សំណើជាលាយលក្ខណ៍អក្សរ ដោយភ្ជាប់នូវសំណៅឯកសារពាក់ព័ន្ធ មកធនាគារជាតិ ក្នុងរយៈពេល ៣០ថ្ងៃមុន ដើម្បីសុំសេចក្តីសំរេច ។

ប្រការ ១៤ : បុគ្គលប្រតិស្រុត ដែលលាក់កំបាំងពត៌មាន ឬផ្តល់ពត៌មានអំពីប្រតិបត្តិការ របស់ខ្លួនមិនច្បាស់លាស់ នឹងត្រូវផ្តន្ទាទោស តាមមាត្រា ៦៩ នៃច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ។

ប្រការ ១៥ : បុគ្គលដែលធ្វើអាជីវកម្មប្តូរប្រាក់ដោយគ្មានការអនុញ្ញាត ពីធនាគារជាតិនៃកម្ពុជានឹងត្រូវផ្តន្ទាទោសតាមមាត្រា ២១ នៃច្បាប់ស្តីពីការគ្រប់គ្រងការប្តូរប្រាក់ ។

ប្រការ ១៦ : ការិយាល័យប្តូរប្រាក់ ឬបញ្ជរប្តូរប្រាក់របស់ធនាគារពាណិជ្ជ មិនស្ថិតក្នុងក្របខ័ណ្ឌនៃប្រកាសនេះឡើយ

ប្រការ ១៧ : ប្រការទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

ប្រការ ១៨ : អគ្គលេខាធិការ-អគ្គនាយក-អគ្គាធិការ-អគ្គលេខា-នាយកដ្ឋានគ្រប់គ្រង ការប្តូរប្រាក់ និងគ្រប់នាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទ ធនាគារជាតិ មានភារកិច្ចអនុវត្តរៀងៗខ្លួន តាមប្រកាសនេះ ។

ប្រការ ១៩ : ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

អគ្គលេខាធិការ

ព្រះតេជោ ធិមុត្រា

ដោង ស៊ុនឆ័ត្រ

***

## ៣-ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

### ប្រកាស

ភ្នំពេញ ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៩៩

**ប្រកាស លេខ ៣៣៥ ពណ-បល-ប្រក**

**ស្តីពីការបង្កើតមន្ទីរពាណិជ្ជកម្ម**

**ខេត្តឧត្តរមានជ័យ**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត /១១៩៨/៦៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការចាត់តាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងពាណិជ្ជកម្ម

-បានឃើញ ព្រះរាជក្រឹត្យ លេខ នស/រកត/០១៩៩/១៧ ចុះថ្ងៃទី២៨ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតខេត្តឧត្តរមានជ័យ

-យោងតាមការចាំបាច់របស់ក្រសួង

**សំរេច**

ប្រការ ១ : បង្កើតមន្ទីរពាណិជ្ជកម្មខេត្តឧត្តរមានជ័យ ដែលមានទីតាំងនៅបំរុងរោង ត្រពាំងប្រាសាទ ។

ប្រការ ២ : មន្ទីរពាណិជ្ជកម្មខេត្តឧត្តរមានជ័យ ជាអង្គភាពរដ្ឋបាលសេដ្ឋកិច្ច ដែលដឹកនាំដោយនាយកមន្ទីរ១រូប និងអមដោយនាយករងមួយចំនួន ជាជំនួយការ ។

ប្រការ ៣ : ការរៀបចំ និងការប្រព្រឹត្តទៅ និងក្របខ័ណ្ឌបុគ្គលិក មន្ត្រីរាជការរបស់មន្ទីរ នឹងត្រូវកំណត់ដោយ បទដ្ឋានដោយឡែក ។

ប្រការ ៤ ៈ អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការ នៃអគ្គាធិការដ្ឋាន នាយកខុទ្ទកាល័យ ត្រូវអនុវត្តប្រកាសនេះ ។

ប្រការ ៥ ៈ ប្រកាសនេះមានអានុភាពអនុវត្ត ចាប់ពីថ្ងៃប្រកាសចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ជម ប្រសិទ្ធ

***

## ៤-និតិការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

### ប្រកាស

ភ្នំពេញ ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៩

**ប្រកាសលេខ ៧២២ ឧក-ប្រក**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ របស់ព្រះករុណាព្រះបាទសម្តេច នរោត្តម សីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញលិខិតលេខ ១២៤៤/៩៩ ក.អ.ក ចុះថ្ងៃទី២៦.៥.១៩៩៩ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។
- បានឃើញលិខិតលេខ ២៦៥ ក.សួ.ស.វ.អប ចុះថ្ងៃទី២៦.៧.១៩៩៩ របស់ក្រសួងបរិស្ថាន ។
- បានឃើញលិខិតលេខ ២០០៥ ព.គ.ស ចុះថ្ងៃទី២២.៧.១៩៩៩ របស់សាលាក្រុងភ្នំពេញ ស្តីពីការអនុញ្ញាតអោយសាងសង់អាគារកាត់ដេរ ។
- តាមសំណើសុំរបស់ក្រុមហ៊ុន ឃើង ស៊ីង (ខេមបូឌា) ហ្គាមេន ហ្វាកតើរី ចុះថ្ងៃទី ១៥.៧.១៩៩៩ ។

**សំរេច**

ប្រការ ១ ៈ អនុញ្ញាតអោយក្រុមហ៊ុន ឃើង ស៊ីង (ខេមបូឌា) ហ្គាមេន ហ្វាកតើរី (CUNG SING ( CAMBODIA) GARMENT FACTORY LTD ) តំណាងដោយលោក SUN SHU YAN សញ្ជាតិចិន ភេទប្រុស អាយុ ៥៧ឆ្នាំ អាស័យដ្ឋាន 8A Prince Industrial Buildmg 106 . kmg Fuk St Sanpokong Kow Loon HONG KONG កាន់លិខិតឆ្លងដែនលេខ H 90031149 ចុះថ្ងៃទី ១៣ .១២.៧៩ បង្កើត

“រោងចក្រកាត់ដេរសំលៀកបំពាក់ ឈ្មោះ “ក្រុមហ៊ុនអាគមបណ្ឌិតគា ” រោងចក្រ ឃើង ស៊ីង (ខេមបូឌា) ហ្គាមេន ” មានទីតាំងស្ថិតនៅផ្លូវលេខ ២៦៥ សង្កាត់ទឹកល្អក់៣ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ។

ប្រការ ២ : ការបង្កើតរោងចក្រនេះ ក្រុមហ៊ុនត្រូវគោរពតាមច្បាប់ និងគោលនយោបាយវិនិយោគ ភាគបង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់ ដែលបានចុះបញ្ជីនៅ ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ។

ប្រការ ៣ : ក្រុមហ៊ុនត្រូវផ្ញើរបាយការណ៍ប្រចាំខែជូនក្រសួងឧស្សាហកម្មរ៉ែ និងថាមពល អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ។

ប្រការ ៤ : រោងចក្រនេះត្រូវបានអនុញ្ញាតអោយ “កាត់ដេរសំលៀកបំពាក់ ” យោតាមសំណុំដែលបានចុះបញ្ជីនៅ ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ។

ប្រការ ៥ : ការកែប្រែមុខផលិតផលនេះ ក្រុមហ៊ុនត្រូវសុំអនុញ្ញាតថ្មីជាមុនពីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ។

ប្រការ ៦ : ក្រុមហ៊ុនត្រូវបិទស្លាកសញ្ញា “ផ្លាកសញ្ញារោងចក្រ” នៅមុខរោងចក្រដែលមានទំហំសមរម្យ និងមើលឃើញច្បាស់ ផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញក្នុងបរិវេណរោងចក្រ ។

ប្រការ ៧ : ក្រុមហ៊ុនត្រូវគោរពនូវការការពារបរិស្ថាន សុវត្ថិភាពការងារ ច្បាប់ស្ដីពីការគ្រប់គ្រងបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និង ច្បាប់ការងារ ដែលពាក់ព័ន្ធនឹងផលិតកម្ម សកម្មភាពរបស់ក្រុមហ៊ុន ។ ក្នុងករណីក្រុមហ៊ុនមិនគោរពច្បាប់ ឬ បង្កការខូចខាតដល់ប្រជាពលរដ្ឋដែលបានរស់នៅក្បែរ ក្រុមហ៊ុននេះនឹងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ។

ប្រការ ៨ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានផែនការ ប្រធាននាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ប្រធានមន្ទីរឧស្សាហកម្មរ៉ែ និងថាមពល រាជធានីភ្នំពេញ និងក្រុមហ៊ុន ឃើង ស៊ីង (ខេមបូឌា) ហ្គាមេន ហ្វេកធើរី ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

ប្រការ ៩ : ប្រកាសនេះមានអនុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា និងត្រា

ស៊ុយ សែម

★★★

## ៥-ទីស្ដីការរដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា

## ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ១៩៩៩

**ប្រកាស លេខ ១៣៥ កធស-ប្រក**

**ស្ដីពីការតែងតាំងមន្ត្រីរាជការ**

**រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួង ធម្មការ និង សាសនា

-បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា លេខ ០៦ នស/១៩៩៤ ចុះថ្ងៃទី៣០ ខែ តុលា ឆ្នាំ ១៩៩៤

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី______ខែ______ឆ្នាំ______

-បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ដែលរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងធម្មការ និង សាសនា ។

-បានឃើញសារាចរណែនាំ លេខ ១០ សរណន ចុះថ្ងៃទី២៨ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការតែងតាំងមន្ត្រីរាជការ ស៊ីវិលរបស់រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញលិខិតលេខ ៧៤ អ.ធ.ស.ព.វ. ចុះថ្ងៃទី២៤ ខែ មិថុនា ឆ្នាំ ១៩៩៩ របស់មន្ទីរធម្មការ និងសាសនា ខេត្តព្រៃវែង ។

-អនុលោមតាមការងារចាំបាច់របស់ក្រសួង និងសមត្ថភាពរបស់មន្ត្រីរាជការ ។

**សំរេច**

**ប្រការ ១ :** តែងតាំងលោក ស សែន បច្ចុប្បន្នអនុប្រធានមន្ទីរ ជាប្រធានមន្ទីរធម្មការ និងសាសនា ខេត្តព្រៃវែង ជំនួសលោក ចិន នាត់ ដែលបានចូលនិវត្តន៍ ។

**ប្រការ ២ :** បៀវត្ស និងប្រាក់ឧបត្ថម្ភ ផ្សេងៗរបស់លោក ស សែន ប្រគល់ជូនមន្ទីរធម្មការ និងសាសនា ខេត្តព្រៃវែង ជាអ្នកចាត់ចែង និង ទូទាត់ ។

**ប្រការ ៣ :** ខុទ្ទកាល័យ អគ្គនាយកធម្មការ នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ( ការិយាល័យបុគ្គលិក ការិយាល័យផែនការគណនេយ្យ ) មន្ទីរធម្មការ និងសាសនា មន្ទីរផែនការ មន្ទីរហិរញ្ញវត្ថុខេត្តព្រៃវែង និងលោក ស សែន ត្រូវអនុវត្តរៀងៗខ្លួន តាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ជា សាវឿន**

★★★

រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩

## ប្រកាស លេខ ១៨២ កធស.ប្រក

## ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

## រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួង ធម្មការ និង សាសនា

-បានឃើញច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា លេខ០៦ នស/ ១៩៩៤ ចុះថ្ងៃទី៣០ ខែ តុលា ឆ្នាំ ១៩៩៤

-បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ដែលរៀបចំ និង ប្រព្រឹត្តទៅ នៃក្រសួងធម្មការ និង សាសនា ។

-បានឃើញសារាចរណែនាំ លេខ ១០ សរណន ចុះថ្ងៃទី២៨ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្ដីពីនីតិវិធីនៃការតែងតាំងមន្ត្រីរាជការ ស៊ីវិលរបស់រាជរដ្ឋាភិបាលកម្ពុជា

-ស្នើរពីអង្គប្រជុំថ្នាក់ដឹកនាំក្រសួង ចុះថ្ងៃទី១៩ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្ដីពីការតែងតាំង និង ផ្ទេរភារកិច្ច មន្ត្រីរាជការ

-អនុលោមតាមការចាំបាច់របស់ក្រសួង និងសមត្ថភាពរបស់មន្ត្រីរាជការ ។

សម្រេច

ប្រការ ១ : តែងតាំងលោក អ៊ឹម ឈុនលី ឲ្យបំពេញភារកិច្ចជាអគ្គីរស្ដីទី នៃអគ្គីធម្មការ និងសាសនា ជាប្រធានអគ្គីរធម្មការ ស្ដីទី នៃអគ្គីធម្មការ និងសាសនា បន្ថែមទៀត ។

ប្រការ ២ : បៀវត្ស និងប្រាក់ឧបត្ថម្ភ ផ្សេងៗរបស់លោក អ៊ឹម ឈុនលី ត្រូវបើកផ្ដល់អគ្គីធម្មការ និងសាសនាតាមអង្គភាពដើមមិនផ្លាស់ប្ដូរ ។

ប្រការ ៣ : ខុទ្ទកាល័យ នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គីធម្មការ និងសាសនា មន្ទីរធម្មការ និងសាសនា ខេត្តកំពង់ឆ្នាំង និងលោក អ៊ឹម ឈុនលី ត្រូវអនុវត្តរៀងៗខ្លួន តាមប្រកាសនេះ ។

ប្រការ ៤ : សេចក្ដីប្រកាសនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា និងត្រា

ជា សាវឿន

★★★